ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រ
# ស្តីពី
# ការបើកទទួលទេសចរណ៍វ៉ាក់សាំង

អនុម័តដោយរាជរដ្ឋាភិបាល ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រ
# ស្តីពី
# ការបើកទទួលទេសចរណ៍វ៉ាក់សាំង

អនុម័តដោយរាជរដ្ឋាភិបាល ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

### អារម្ភកថា

អស់រយៈកាល ១៨ខែ កន្លងមកនេះ វិបត្តិនៃជំងឺកូវីដ-១៩ បាននាំមកនូវគ្រោះមហន្តរាយដល់ពិភពលោកទាំងមូល ក្នុងនោះវិស័យទេសចរណ៍សកលលោក ក៏ដូចជានៅកម្ពុជាបាននិងកំពុងទទួលរងឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ។ ការណ៍នេះបានជំរុញឱ្យរដ្ឋាភិបាលនៃបណ្តាប្រទេសនានាបានធ្វើការបិទ-បើកតំបន់ ឬប្រទេសទាំងមូលជាច្រើនលើកច្រើនសារ ខណៈដែលយុទ្ធនាការចាក់វ៉ាក់សាំងទ្រង់ទ្រាយធំកំពុងត្រូវបានបន្តអនុវត្តដើម្បីបង្កើតភាពស៊ាំនៅក្នុងសហគមន៍ សំដៅជំរុញការស្តារសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញ ស្របតាមគន្លងប្រក្រតីភាពថ្មី។

ឈរលើទស្សនវិស័យនៃ **"ការគិតពីប្រជាជន គិតពីសេដ្ឋកិច្ច គិតពីអនាគត"** រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់នូវស្មារតីបុរេសកម្ម និងជាក់ស្តែងនិយម ដោយមានផែនការច្បាស់លាស់ក្នុងការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា តាមរយៈការដាក់ចេញនូវ **"ផែនទីចង្អុលផ្លូវ ស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩" និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍** សម្រាប់គោលដៅសំខាន់ៗ ដែលជាឯកសារគោលដ៏មានសារៈសំខាន់ជាយុទ្ធសាស្ត្រសម្រាប់អនាគតវិស័យទេសចរណ៍កម្ពុជា។

ទន្ទឹមនេះ ភាពចាំបាច់ក្នុងការបើកដំណើរការសកម្មភាពសេដ្ឋកិច្ចពេញលេញជាបណ្តើរៗឡើងវិញ ត្រូវបានវាយតម្លៃថាស្ថិតក្នុង**ស្ថានភាពបន្ទាន់ និងត្រូវស្របតាមគន្លងប្រក្រតីភាពថ្មី** ដោយហេតុថាស្ថានភាពទីផ្សារទេសចរណ៍នឹងមានភាពតូចចង្អៀត ជាមួយការប្រកួតប្រជែងកាន់តែខ្ពស់ ទាំងលើទិដ្ឋភាពនៃគុណភាពផលិតផល និងសេវាកម្ម, ថ្លៃ, ទំនុកចិត្តលើសុវត្ថិភាពនៃគោលដៅទេសចរណ៍, វិធានការក្នុងការគ្រប់គ្រងស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩, និងការសម្រួលការធ្វើដំណើរ។ ចំណុចទាំងនេះគឺជាកត្តាគន្លឹះសម្រាប់ការសម្រេចចិត្តរបស់ភ្ញៀវទេសចរក្នុងការជ្រើសរើសគោលដៅដំណើរកម្សាន្តទេសចរណ៍ក្នុងបរិបទថ្មី។ ក្នុងន័យនេះ **ផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង** នឹងក្លាយជាឯកសារយុទ្ធសាស្ត្រដ៏សំខាន់ សម្រាប់ការបើកឱ្យដំណើរការឡើងវិញជាបណ្តើរៗនៃការទទួលភ្ញៀវទេសចរអន្តរជាតិ ដោយឈរលើគោលការណ៍រក្សាបាននូវតុល្យភាពរវាងសកម្មភាពសង្គម-សេដ្ឋកិច្ច និងការធានាសុវត្ថិភាព និងសុខភាពសាធារណៈ ជាមួយកិច្ចខិតខំក្នុងការវិលត្រឡប់ឱ្យបានឆាប់ទៅរក **"ប្រក្រតីភាពថ្មី"** នៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

ការបើកទទួលទេសចរណ៍អន្តរជាតិឡើងវិញ នឹងត្រូវធ្វើឡើងតាមដំណាក់កាល ជាជំហានៗ ដោយផ្អែកលើវិធីសាស្ត្រជាក់លាក់ក្នុងការកំណត់តំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ដែលជាអនុគមន៍នឹងអត្រានៃការ

ចាក់វ៉ាក់សាំង, អត្រាអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និងកម្រិតធ្ងន់ និងអត្រាស្លាប់នៃអ្នកជំងឺកូវីដ-១៩, សមត្ថភាពឆ្លើយតប និងគ្រប់គ្រងហានិភ័យដែលអាចកើតមានពីវីរុសបំប្លែងថ្មី និងការត្រៀមលក្ខណៈសម្បត្តិរបស់ឧស្សាហកម្មទេសចរណ៍កម្ពុជាស្របតាមគន្លងប្រក្រតីភាពថ្មី។ ក្នុងស្មារតីនេះ ព្រះរាជាណាចក្រកម្ពុជានឹងបើកទទួលទេសចរណ៍វ៉ាក់សាំងនៅចុងខែវិច្ឆិកា ឆ្នាំ២០២១ ដោយចាប់ផ្តើមនៅក្រុងព្រះសីហនុ និងក្រុងកោះរ៉ុងនៃខេត្តព្រះសីហនុ, និងតំបន់តារាសាគរនៃខេត្តកោះកុង, និងបន្ទាប់មកនៅខេត្តសៀមរាប នៅក្នុងខែមករា ឆ្នាំ២០២២។ ឈរលើស្មារតីប្រុងប្រយ័ត្ន ការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រនេះ នឹងត្រូវមានការត្រួតពិនិត្យ តាមដាន វាយតម្លៃជាប់ជាប្រចាំ ស្របតាមការវិវត្តជាក់ស្តែងនៃសភាពការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដំណាក់កាលនីមួយៗ ផ្សារភ្ជាប់ជាមួយនឹងជម្រើសសម្រាប់ការបើក-បិទ ដោយផ្អែកលើការបែងចែកតំបន់, ការធ្វើអាទិភាវូបនីយកម្មជម្រើសសកម្មភាពទេសចរណ៍តាមអនុវិស័យ និងកត្តាពេលវេលាដែលដើរតួជាចន្លុះយុទ្ធសាស្ត្រសំខាន់ក្នុងការផ្តល់លទ្ធភាពដល់ការគ្រប់គ្រងហានិភ័យ។

ឆ្លៀតឱកាសនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ**ក្រុមការងារក្រសួងទេសចរណ៍ និងក្រុមការងាររាជរដ្ឋាភិបាល និងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩** ដែលបានរៀបចំឯកសារផែនការយុទ្ធសាស្ត្រដ៏សំខាន់នេះចំពេលវេលាដ៏ចាំបាច់ សម្រាប់វិស័យទេសចរណ៍ជាតិ ក្នុងដំណាក់កាលដ៏លំបាកនេះ។

ខ្ញុំសូមអំពាវនាវដល់គ្រប់ក្រសួង-ស្ថាប័ន វិស័យឯកជន ប្រជាពលរដ្ឋ និងភ្ញៀវទេសចរជាតិ-អន្តរជាតិ ត្រូវប្រកាន់ខ្ជាប់នូវឆន្ទៈទទួលខុសត្រូវខ្ពស់ ដោយផ្តល់អាទិភាពដល់ការអនុវត្ត **ផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង**ឱ្យទទួលបានជោគជ័យ ដើម្បីរួមចំណែកដល់ការធានានិរន្តរភាព និងការស្តារកំណើនសេដ្ឋកិច្ច។

ថ្ងៃសៅរ៍ ២ រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា


១. សេចក្តីផ្តើម ........................................ ១

២. ចក្ខុវិស័យ ........................................ ៣

៣. គោលបំណង និងគោលដៅ ........................................ ៣

៣.១. គោលបំណង ........................................ ៣

៣.២. គោលដៅ ........................................ ៣

៤. ក្របខណ្ឌយុទ្ធសាស្ត្រ ........................................ ៤

៤.១. ការវិភាគចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព និងហានិភ័យ (SWOT) ........................................ ៥

៤.២. ការវាយតម្លៃស្ថានភាពជាក់ស្តែងនៃការទទួលទេសចរអន្តរជាតិមកកម្ពុជា ........................................ ៦

៤.៣. ការវាយតម្លៃលទ្ធភាពជោគជ័យនៃការបើកទទួលទេសចរណ៍វ៉ាក់សាំង ........................................ ៧

៤.៤. អតិក្រមនៃការអនុវត្ត ........................................ ៩

៥. ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ ........................................ ១១

៥.១. ការកំណត់នូវប្រភពទីផ្សារទេសចរណ៍វ៉ាក់សាំង ........................................ ១១

៥.២. ការគ្រប់គ្រងទេសចរមុនពេលចេញដំណើរ និងពេលមកដល់អាកាសយានដ្ឋានអន្តរជាតិ.... ១៣

៥.៣. ការត្រៀមលក្ខណៈសម្បត្តិនៃឧស្សាហកម្មទេសចរណ៍ស្របតាមគន្លងប្រក្រតីភាពថ្មី ........................................ ១៦

៥.៤. ការកំណត់ និងគ្រប់គ្រងគោលដៅទេសចរណ៍សុវត្ថិភាព ........................................ ១៨

៦. យន្តការអនុវត្ត ........................................ ២០

៧. ធនធានហិរញ្ញវត្ថុ ........................................ ២៣

៨. យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........................................ ២៣

៨.១ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........................................ ២៣

៨.២ ការវាយតម្លៃហានិភ័យ ........................................ ២៣

៨.៣ ការគ្រប់គ្រងហានិភ័យ ........................................ ២៤

៩. សេចក្តីសន្និដ្ឋាន ........................................ ២៥

សន្ទានុក្រម ........................................ ២៦

ឧបសម្ព័ន្ធទី១÷ ផែនការសកម្មភាព ........................................ ២៩

ឧបសម្ព័ន្ធទី២÷ ដំណើរការសម្រាប់ការស្នើសុំលិខិតអនុញ្ញាតចូលកម្ពុជា (Safe Travel Pass) ........................................ ៣៨

ឧបសម្ព័ន្ធទី៣÷ ដំណើរការនៃការប្រើប្រាស់ប្រព័ន្ធកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំងកូវីដ-១៩.. ៤០

ឧបសម្ព័ន្ធទី៤÷ នីតិវិធីបញ្ចូលទិន្នន័យបុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍ដែលបានចាក់វ៉ាក់សាំង.. ៤១

ឧបសម្ព័ន្ធទី៥÷ ឡាបិល VACCINATED ........................................ ៤២

ឧបសម្ព័ន្ធទី៦÷ ឡាបិល តំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ........................................ ៤៣

## ១. សេចក្តីផ្តើម

**(១)** វិបត្តិនៃជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យទេសចរណ៍សកលលោក។ អង្គការទេសចរណ៍ពិភពលោក(UNWTO) វាយតម្លៃថាវិស័យទេសចរណ៍ និងការធ្វើដំណើរជាសកល បានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារវិធានការរឹតត្បិតការធ្វើដំណើរនៃបណ្តាប្រទេសនានាទូទាំងពិភពលោក និងការថមថយតម្រូវការនៃការធ្វើដំណើរចេញក្រៅរបស់ភ្ញៀវទេសចរនៅក្នុងពេលនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**(២)** យោងតាម ក្រុមប្រឹក្សាភិបាលនៃការធ្វើដំណើរនិងទេសចរណ៍ពិភពលោក (WTTC) វិបត្តិនៃជំងឺកូវីដ-១៩ បានធ្វើឱ្យចលនាទេសចរណ៍អន្តរជាតិ ក្នុងកម្រិតតំបន់ និងសកលលោកមានការប្រែប្រួល ជាមួយនិន្នាការថ្មីៗ ក្នុងនោះរួមមាន÷

**ទី១). ការផ្លាស់ប្តូរឥរិយាបថរបស់ភ្ញៀវទេសចរ÷** ការភ័យខ្លាចពីការឆ្លងជំងឺកូវីដ-១៩ ក៏ដូចជាការរឹតត្បិតការធ្វើដំណើររបស់ប្រទេសនីមួយៗ បានជំរុញឱ្យមានការផ្លាស់ប្តូរការសម្រេចចិត្តរបស់ភ្ញៀវទេសចរ ដោយធ្វើដំណើរ ឬហោះហើរក្នុងរយៈចម្ងាយខ្លីជាងមុន និងទៅកាន់តំបន់ដែលធ្លាប់ស្គាល់, ទុកចិត្ត និងមានហានិភ័យទាប,

**ទី២). វិស័យទេសចរណ៍ពិភពលោកទាំងមូលកំពុងបោះជំហានឈានដល់ដំណាក់កាលតាម "គន្លងប្រក្រតីភាពថ្មី" ÷** ក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ការធ្វើដំណើរកម្សាន្ត និងទេសចរណ៍នឹងមានទំនោរទៅរកទស្សនទាននៃភាពស្អាត, អនាម័យ, ភាពបៃតង និងការរក្សាសុវត្ថិភាព, ការទទួលបានបទពិសោធន៍ទេសចរណ៍ផ្ទាល់ខ្លួន, ការកក់សេវាកម្មទេសចរណ៍ដែលមានភាពទន់ភ្លន់ និងបត់បែន, ការសម្រួលដល់ការធ្វើដំណើរ និងចំនួនថ្ងៃនៃការធ្វើចត្តាឡីស័ក។ល។,

**ទី៣). ការប្រើប្រាស់បច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងការធ្វើដំណើរកម្សាន្ត÷** វិបត្តិនៃជំងឺកូវីដ-១៩ បានបើកឱកាសដល់ការចាប់យក និងសម្របខ្លួនជាមួយបច្ចេកវិទ្យា និងនវានុវត្តន៍បានយ៉ាងល្អប្រសើរ ដូចជាការកក់ទុកជាមុនពីចម្ងាយ និងការទូទាត់អនឡាញជាដើម។ ភ្ញៀវទេសចរ និងអ្នកធ្វើដំណើរអន្តរជាតិភាគច្រើនធ្វើការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណិត មុននឹងរៀបចំផែនការធ្វើដំណើរ,

**ទី៤). បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ÷** ជាមួយនឹងការផ្លាស់ប្តូរស្ថានភាពនៃវិស័យទេសចរណ៍ និងឥរិយាបថរបស់ទេសចរ ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងក្របខណ្ឌទ្វេភាគី និងពហុភាគីជាមួយប្រទេសជាដៃគូ និងអង្គការជាតិ-អន្តរជាតិគឺជាកត្តាយុទ្ធសាស្ត្រសំខាន់សម្រាប់ការស្តារវិស័យទេសចរណ៍ឡើងវិញ,

**ទី៥). ការបើកទទួលភ្ញៀវទេសចរអន្តរជាតិ÷** បន្ទាប់ពីការបិទវិស័យទេសចរណ៍អស់រយៈពេលជិត ២ ឆ្នាំកន្លងមក ការបើកឡើងវិញជាសន្សឹមៗនឹងចូលរួមដល់ ការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ឡើងវិញ តាមរយៈការផ្តល់ព័ត៌មានដែលទុកចិត្តបាន, ប្រកបដោយគណនេយ្យភាព និងមានតម្លាភាព ដូចជាការប្រើប្រាស់ប័ណ្ណបញ្ជាក់សុខភាពឌីជីថល (Digital Health Pass), នីតិវិធីនៃការធ្វើតេស្ត ដែលស្របតាមស្តង់ដាអន្តរជាតិ ឬតំបន់ជាដើម,

**ទី៦). និន្នាការនៃការចាប់យកទីផ្សារទេសចរណ៍កម្រិតខ្ពស់**ដែលជាប្រភពទីផ្សារមានសក្តានុពល ហ៊ាន ចំណាយច្រើន ដូចជាទេសចរធុរកិច្ច ទេសចរលក្ខណៈបុគ្គល ឬគ្រួសារ ឬក្រុមតូចៗ ដែលមានជីវភាព កម្រិតខ្ពស់ ហើយចង់ធ្វើដំណើរទៅកាន់តំបន់ទេសចរណ៍ដែលមានសុវត្ថិភាព នឹងក្លាយជាយុទ្ធសាស្ត្រ មួយសំខាន់សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍តាមគន្លងប្រក្រតីភាពថ្មី, និង

**ទី៧). ការកើនឡើងនៃប្រភេទក្រុមទេសចរយុវជន** (ក្រុម Millennials និងក្រុម Generation Z)÷ ដោយក្រុមភ្ញៀវទេសចរទាំងពីរប្រភេទនេះមានតម្រូវការ និងឥរិយាបថនៃការដើរកម្សាន្តខុសៗគ្នា ប៉ុន្តែ ចំណុចដែលលេចធ្លោនោះគឺសមត្ថភាពបន្សុំខ្លួនទៅនឹងបច្ចេកវិទ្យាថ្មីៗបានយ៉ាងឆាប់រហ័សរបស់ពួកគេ ដែលគោលដៅទេសចរណ៍ត្រូវផ្តោតសំខាន់លើការប្រើប្រាស់បច្ចេកវិទ្យា និងការផ្សព្វផ្សាយតាមបែប ឌីជីថលដើម្បីទាក់ទាញប្រភពទីផ្សារនេះ។

**(៣)** បច្ចុប្បន្ន ទោះបីជាមានការផ្តល់ក្តីសង្ឃឹមតាមរយៈការអភិវឌ្ឍវ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ និង យុទ្ធនាការចាក់វ៉ាក់សាំងទ្រង់ទ្រាយធំ ដែលបាននឹងកំពុងបន្តអនុវត្តនៅតាមបណ្តាប្រទេសជាច្រើន ប៉ុន្តែស្ថានភាព នៃការចម្លងជំងឺកូវីដ-១៩ ក៏នៅតែបន្តវិវត្តន៍យ៉ាងលឿន តាមរយៈការបំប្លែងខ្លួនប្រភេទវីរុសកូវីដ-១៩ ថ្មី (វីរុស បំប្លែងថ្មី)។ ជាការពិត ជំងឺកូវីដ-១៩ មិនត្រឹមតែជាជំងឺដ៏កាចសាហាវ និងបង្កមហន្តរាយ ចំពោះសុខភាពសាធារណៈ ប៉ុន្តែបាននិងកំពុងបន្តបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរជាប្រវត្តិសាស្ត្រ ចំពោះសេដ្ឋកិច្ចពិភពលោក ដែលក្នុងនោះ សកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្ម ស្ទើរគ្រប់វិស័យទាំងអស់បានធ្លាក់ចុះ ជាមួយការកើនឡើងនៃអត្រាអត់ ការងារធ្វើ, ការបាត់បង់ចំណូល និងការធ្លាក់ចូលក្នុងភាពក្រីក្រ ដែលទាំងនេះនឹងនាំមកនូវបញ្ហាប្រឈមកាន់តែ ស្មុគស្មាញបន្ថែមទៀត។

**(៤)** ចំពោះកម្ពុជា វិបត្តិនៃជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងខ្លាំងមកលើវិស័យសង្គម-សេដ្ឋកិច្ច ក្នុងទម្រង់ផ្សេងៗគ្នា និងកម្រិតខុសៗគ្នា។ កម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ជាប្រមុខរាជរដ្ឋាភិបាល បាន និងកំពុងប្រយុទ្ធយ៉ាងសស្រាក់សស្រាំ ដើម្បីទប់ស្កាត់ការឆ្លង រាលដាលនៃជំងឺកូវីដ-១៩ សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ ព្រមទាំងកាត់បន្ថយ ឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងរាលដាលជំងឺនេះ តាមរយៈការដាក់ចេញជាបន្តបន្ទាប់នូវច្បាប់, បទប្បញ្ញត្តិ, វិធានការសុខាភិបាល, វិធានការរដ្ឋបាល និងវិធានការផ្សេងៗទៀត។ តាមរយៈវិធានការនានា ដែលបានដាក់ចេញទាន់ពេល ព្រមជាមួយសន្ទុស្សន៍ល្អប្រសើរនៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ កម្ពុជា អាចគ្រប់គ្រងស្ថានភាពនៃជំងឺកូវីដ-១៩ បានល្អប្រសើរ និងជួយសម្រួលដល់សកម្មភាពសេដ្ឋកិច្ច ដូចជា ពាណិជ្ជកម្មក្នុងស្រុក និងអាជីវកម្មនានា ឱ្យមានដំណើរការល្អ ក៏ដូចជាជួយសម្រាលបន្ទុកជីវភាពរបស់ប្រជា-ពលរដ្ឋទូទៅ។ ជាមួយនឹងស្មារតីបុរេសកម្ម, រាជរដ្ឋាភិបាលក៏បានរៀបចំយុទ្ធសាស្ត្រស្តារ និងជំរុញកំណើនសេដ្ឋ-កិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី។

**(៥) សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានគូសបញ្ជាក់ពីសារៈសំខាន់នៃការស្តារ សកម្មភាពសង្គម-សេដ្ឋកិច្ច ឡើងវិញជាបណ្តើរៗ តាមគន្លង **"ប្រក្រតីភាពថ្មី"** នៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ ប្រជាពលរដ្ឋ ជាពិសេសវិស័យទេសចរណ៍ទាំងក្នុងប្រទេស និងអន្តរជាតិ។ នាពេលកន្លងមក, ទោះបីជាមានការ

ឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចលនាទេសចរណ៍ក្នុងស្រុកបានថមថយ តែមានសន្ទុះងើបឡើងវិញនៅរៀងរាល់ពេលដែលសភាពការណ៍នៃការចម្លងជំងឺកូវីដ-១៩ មានភាពស្ងប់ស្ងាត់ និងនៅតាមតំបន់គោលដៅខេត្ត-ស្រុក ដែលពុំសូវមានការឆ្លងរាលដាលនៃជំងឺឆ្លង។ រាជរដ្ឋាភិបាលយកចិត្តទុកដាក់ និងបន្តជំរុញចលនាទេសចរណ៍ក្នុងស្រុក ដើម្បីជាមូលដ្ឋានសម្រាប់ការត្រៀមបើកទទួលទេសចរណ៍អន្តរជាតិ។

**(៦)** ជាមួយនឹងហេតុផលខាងលើ រាជរដ្ឋាភិបាលកម្ពុជាសម្រេចដាក់ចេញនូវ **"ផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង"** ដើម្បីបើកទទួលភ្ញៀវទេសចរអន្តរជាតិពីប្រភពទីផ្សារដែលមានសក្តានុពល និងមានហានិភ័យទាប និងអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព, សុវត្ថិភាព និងនិរន្តរភាព តាមគន្លងប្រក្រតីភាពថ្មី ស្របតាមទស្សនទាន **"ប្រែក្លាយបញ្ហាប្រឈមទៅជាកាលានុវត្តភាព"**។

## ២. ចក្ខុវិស័យ

**(៧) ផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង** មានចក្ខុវិស័យស្តារ និងអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា តាមរយៈការចាប់ផ្តើមពីការបើកទទួលទេសចរណ៍វ៉ាក់សាំង ជាមួយនឹងការគ្រប់គ្រងប្រកបដោយគុណភាព, សុវត្ថិភាព និងនិរន្តរភាព តាមគន្លងប្រក្រតីភាពថ្មី។

## ៣. គោលបំណង និងគោលដៅ

### ៣.១. គោលបំណង

**(៨)** ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ផែនការយុទ្ធសាស្ត្រនេះមានគោលបំណងចាប់ផ្តើមជំរុញការបើកទទួលទេសចរណ៍អន្តរជាតិឡើងវិញជាជំហានៗ ឈរលើគោលការណ៍រក្សាបាននូវតុល្យភាពរវាងសកម្មភាពសង្គម-សេដ្ឋកិច្ច និងការធានាសុវត្ថិភាព និងសុខភាពសាធារណៈ សម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ ស្របតាមស្មារតីនៃ **"ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព"** ដើម្បីចូលរួមអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ឱ្យក្លាយជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព, សុវត្ថិភាព និងនិរន្តរភាព។

### ៣.២. គោលដៅ

**(៩)** ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងខាងលើ ផែនការយុទ្ធសាស្ត្រនេះកំណត់នូវគោលដៅសំខាន់ៗ ចំនួន ៤ រួមមាន÷ **គោលដៅទី១).** ការកំណត់ប្រភពទីផ្សារដែលមានសក្តានុពល, សុវត្ថិភាព និងហានិភ័យទាប, **គោលដៅទី២).** ការគ្រប់គ្រងវិហ្វូរភ្ញៀវទេសចរអន្តរជាតិ ដើម្បីបង្ការ, ទប់ស្កាត់ និងកាត់បន្ថយការឆ្លងរាលដាលនៃជំងឺកូវីដ-១៩, **គោលដៅទី៣).** ការពង្រឹងសុវត្ថិភាព និងគុណភាពសេវាកម្មទេសចរណ៍កម្ពុជា ស្របតាមគន្លងប្រក្រតីភាពថ្មី និង **គោលដៅទី៤).** ការបង្កើនទំនុកចិត្ត និងភាពជឿជាក់គ្នាទៅវិញទៅមករវាងប្រភពទីផ្សារ និងគោលដៅទេសចរណ៍កម្ពុជា។

## ៤. ក្របខណ្ឌយុទ្ធសាស្ត្រ

**(១០)** រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន ៦ ចំណុច ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ រួមមាន÷ **ទី (១).** បន្តទប់ស្កាត់ការនាំចូលនូវមេរោគកូវីដ-១៩ បំប្លែងថ្មី, **ទី (២).** កាត់បន្ថយទំហំតំបន់ឆ្លង និងចំនួនឆ្លងឱ្យនៅកម្រិតទាប, **ទី (៣).** បន្តខិតខំព្យាបាលអ្នកឆ្លងឱ្យបានជាសះស្បើយ កាត់បន្ថយអត្រាស្លាប់, **ទី (៤).** រុករក និងគ្រប់គ្រងករណីពាក់ព័ន្ធនឹងជំងឺកូវីដ-១៩, **ទី (៥).** ការរៀបចំបូជាសព និងបញ្ចុះសពអ្នកស្លាប់ឱ្យបានសមរម្យ និងល្អប្រសើរ, និង **ទី (៦).** ជំរុញយុទ្ធនាការចាក់វ៉ាក់សាំង ដោយអនុវត្តនូវ **"យុទ្ធសាស្ត្រផ្ការីក"** របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ដោយចាប់ផ្តើមពីតំបន់អាទិភាព ទាំងសម្រាប់មនុស្សពេញវ័យ, យុវជន និងកុមារ។ ការដាក់ចេញនូវយុទ្ធសាស្ត្រទាំង ៦ ចំណុច របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺសំដៅគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍, រក្សាលំនឹង និងការស្តារសកម្មភាពសង្គម-សេដ្ឋកិច្ច និងត្រៀមខ្លួនដើម្បីរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី។ ម្យ៉ាងទៀត, រាជរដ្ឋាភិបាលក៏បានអនុម័ត **ផែនទីបង្ហាញផ្លូវ ស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩** ដែលចែកជា ៣ (បី) ដំណាក់កាល សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ (២០២០-២០២៥) រួមមាន ដំណាក់កាលទី១ **ភាពធន់**÷ ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលនៃទម្លាប់ថ្មី តាមគន្លងប្រក្រតីភាពថ្មី និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ, ដំណាក់កាលទី២ **ការងើបឡើងវិញ**÷ ការជំរុញ និងការស្តារឡើងវិញនៃវិស័យទេសចរណ៍, និងដំណាក់កាលទី៣ **ការដំណើរការឡើងវិញ**÷ ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា។

**(១១)** ឈរលើស្មារតីនេះ **ផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង** នេះ ត្រូវបានរៀបចំឡើងដើម្បីត្រៀមលក្ខណៈក្នុងការបើកទទួលទេសចរណ៍វ៉ាក់សាំង តាមដំណាក់កាលវិវត្តនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងការគ្រប់គ្រងនៃវិបត្តិ។ ផែនការយុទ្ធសាស្ត្រនេះគ្របដណ្តប់លើការគិតគូរក្នុង**ការតាមដានហានិភ័យរបស់ប្រភពទីផ្សារទេសចរណ៍សំខាន់ៗសម្រាប់កម្ពុជា ក្នុងការបើកទទួលទេសចរណ៍វ៉ាក់សាំង, ជម្រើសតំបន់គោលដៅសម្រាប់ការបើកជាជំហានៗ និងការគ្រប់គ្រងវិហ្វូរភ្ញៀវទេសចរ** ទាំងមុនពេលមកដល់, នៅពេលមកដល់, ពេលកំពុងស្នាក់នៅ និងពេលចាកចេញពីប្រទេសកម្ពុជាវិញ។ ទន្ទឹមនេះ, ក៏មានការគិតគូរពីការធានាសុវត្ថិភាព និងផ្តល់ទំនុកចិត្តជូនភ្ញៀវទេសចរក្នុងពេលធ្វើដំណើរកម្សាន្ត និងស្នាក់នៅក្នុងប្រទេសកម្ពុជា ដោយសកម្មភាព និងអាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវគោរពតាមវិធានការ និងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាល។

**(១២)** *"ទេសចរណ៍វ៉ាក់សាំង" សំដៅដល់សកម្មភាពនៃការធ្វើដំណើរ និងទស្សនាកម្ពុជា នៃភ្ញៀវទេសចរអន្តរជាតិ ដែលបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ គ្រប់ដូស ហើយចេញមកពីប្រភពទីផ្សារដែលមានសក្តានុពល និងមានហានិភ័យទាប ក្រោមរូបភាពជាការធ្វើដំណើរដែលមានការគ្រប់គ្រងច្បាស់លាស់ សំដៅធានាដល់ការពេញចិត្ត និងសុខសុវត្ថិភាពជូនភ្ញៀវទេសចរ ក៏ដូចជាប្រជាពលរដ្ឋម្ចាស់ផ្ទះ តាមគន្លងប្រក្រតីភាពថ្មី។*

**(១៣)** ការទាក់ទាញទេសចរណ៍អាចធ្វើបានសម្រាប់ប្រភេទទេសចរដែលមានការគ្រប់គ្រង មកពីប្រភពទីផ្សារដែលមានសក្តានុពល និងហានិភ័យទាប ដោយអាចមកពីតំបន់ ឬក្រុមប្រទេស ដែលមានការ

ឯកភាពគ្នាលើការលើកលែង ឬកាត់បន្ថយចំនួនថ្ងៃឱ្យបានតិចបំផុតសម្រាប់ការធ្វើចត្តាឡីស័ក ទាំងពេលចេញមក និងពេលត្រឡប់ទៅវិញ។

### ៤.១. ការវិភាគចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព និងហានិភ័យ (SWOT)

**(១៤)** វិស័យទេសចរណ៍កម្ពុជានាពេលបច្ចុប្បន្នក្នុងដំណាក់កាល**តាមគន្លងប្រក្រតីភាពថ្មី** (New Normal) មាន **ចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព និងហានិភ័យ** ដូចខាងក្រោម÷

| ចំណុចខ្លាំង | ចំណុចខ្សោយ |
| --- | --- |
| • នៅតែមានគោលដៅទេសចរណ៍ទាក់ទាញជាច្រើនកន្លែង ជាពិសេសប្រាង្គប្រាសាទអង្គរវត្តដ៏ល្បីល្បាញ រួមជាមួយនឹងសម្បត្តិធនធានដ៏វិសេសវិសាលជាច្រើនទៀត ដែលជាផលិតផលទេសចរណ៍វប្បធម៌, ធម្មជាតិ, អេកូ-ទេសចរណ៍, ឆ្នេរសមុទ្រ និងតំបន់ទេសចរណ៍កែច្នៃដ៏សម្បូរបែបនានា<br>• ចលនាទេសចរណ៍ក្នុងស្រុកបានចូលរួមយ៉ាងខ្លាំងដល់ការស្តារវិស័យទេសចរណ៍ក្នុងពេលវិបត្តិ និងដើរតួជាចលករនាំមុខដើម្បីឈានទៅការបើកទទួលទេសចរអន្តរជាតិឡើងវិញ<br>• មានច្បាប់, បទដ្ឋានគតិយុត្តិ និងយុទ្ធ-សាស្ត្រច្បាស់លាស់ សម្រាប់ការប្រយុទ្ធប្រឆាំង និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩<br>• សន្ទុស្សន៍នៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មានភាពល្អប្រសើរ និងកើនឡើងយ៉ាងឆាប់រហ័សនៅក្របខណ្ឌទូទាំងប្រទេស<br>• អត្ថិភាពនៃបច្ចេកវិទ្យាថ្មីៗ ដែលកំពុងត្រូវបានប្រើប្រាស់ ជួយទ្រទ្រង់សកម្មភាពសង្គម-សេដ្ឋកិច្ច ក្នុងបរិបទកូវីដ-១៩។ | • កង្វះការតភ្ជាប់ត្រង់ តាមផ្លូវអាកាសពីប្រភពទីផ្សារសំខាន់ៗ<br>• ស្ថានភាពលំបាកនៃការផ្គត់ផ្គង់សេវា និងផលិតផលទេសចរណ៍ ក្រោយទទួលរងឥទ្ធិពលអវិជ្ជមានខ្លាំងពីវិបត្តិនៃជំងឺកូវីដ-១៩<br>• បុគ្គលិកក្នុងវិស័យទេសចរណ៍មួយភាគបានបាត់បង់ជំនាញ ដោយសារការផ្អាក ឬបាត់បង់ការងារ ក្នុងពេលវិបត្តិនៃជំងឺកូវីដ-១៩<br>• កង្វះប្រព័ន្ធកក់ទុកជាមុនពីចម្ងាយ និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យទេសចរណ៍កម្ពុជា<br>• ការរឹតត្បិតការធ្វើដំណើរ និងរបាំងទេសចរណ៍ក្នុងប្រទេស។ |

| កាលានុវត្តភាព | ហានិភ័យ |
|---|---|
| • ហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ត្រូវបានរៀបចំ សម្រាប់ទទួលស្វាគមន៍ភ្ញៀវទេសចរ ដូចជា គម្រោងជួសជុលផ្លូវនៅខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តកំពត។ល។<br>• ការដកចេញវិធានការរឹតត្បិតការធ្វើដំណើរជាបណ្ដើរៗ របស់ប្រទេសនានា បានជំរុញឱ្យមានតម្រូវការធ្វើដំណើរកម្សាន្ត និងទេសចរណ៍ឡើងវិញ<br>• ការកសាងទំនុកចិត្ត និងភាពជឿជាក់របស់ភ្ញៀវទេសចរ<br>• កិច្ចសហការជាមួយវិស័យឯកជន, ដៃគូអភិវឌ្ឍន៍, អង្គការជាតិ និងអន្តរជាតិ<br>• មូលដ្ឋានអាជីវកម្មទេសចរណ៍ចាប់បើកដំណើរការឡើងវិញជាបណ្ដើរៗ<br>• កំណើនសេដ្ឋកិច្ចមានសន្ទុះឡើងវិញ។ | • ការប្រកួតប្រជែងពីប្រទេសជិតខាងខ្ពស់ ក្នុងដំណាក់កាល ក្នុង និងក្រោយវិបត្តិ<br>• ការប្រែប្រួលយ៉ាងលឿននៃស្ថានភាពនៃការចម្លងជំងឺកូវីដ-១៩ តាមរយៈការបំប្លែងខ្លួននៃប្រភេទវីរុសកូវីដ-១៩ ថ្មី<br>• សម្ពាធលើប្រព័ន្ធសុខាភិបាល<br>• ហានិភ័យខ្ពស់ នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយការទទួលទេសចរណ៍អន្តរជាតិ ប្រសិនបើការគ្រប់គ្រងលំហូរភ្ញៀវ មិនបានល្អ។ |

### ៤.២. ការវាយតម្លៃស្ថានភាពជាក់ស្តែងនៃការទទួលទេសចរអន្តរជាតិមកកម្ពុជា

**(១៥)** កំណើននៃភ្ញៀវទេសចរអន្តរជាតិមកកម្ពុជាបន្តកើនឡើងជាលំដាប់ រហូតមកដល់ដើមឆ្នាំ២០២០ ដែលវិស័យទេសចរណ៍កម្ពុជា ក៏ដូចជាពិភពលោកទាំងមូលចាប់ផ្តើមទទួលរងឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងពីវិបត្តិនៃជំងឺកូវីដ-១៩។ ជាក់ស្តែង ក្នុងឆ្នាំ២០២០ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិ ចំនួន **១,៣១ លាននាក់** ថយចុះ **-៨០,២%** ជាមួយនឹងការបាត់បង់ប្រាក់ចំណូលប្រមាណ **៣ ពាន់លានដុល្លារអាមេរិក**។ ជាការពិត មួយភាគធំនៃការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិនៅក្នុងឆ្នាំ២០២០ គឺជាភ្ញៀវទេសចរដែលមកកម្ពុជា អំឡុងខែមករា ដល់ខែមីនា ឆ្នាំ២០២០ មុនពេលមានការរឹតត្បិតនៃការធ្វើដំណើរជាសកល។ ដោយឡែក ក្នុង**ឆមាសទី១ ឆ្នាំ២០២១** កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិចំនួនប្រមាណ **១០ ម៉ឺននាក់ ថយចុះ -៩១,៣%** ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

**(១៦)** ការធ្លាក់ចុះយ៉ាងគំហុកនៃចំនួនភ្ញៀវទេសចរ បង្កផលប៉ះពាល់ដល់ដំណើរការអាជីវកម្មទេសចរណ៍ទូទាំងប្រទេស ក្នុងនោះ នៅក្នុងឆ្នាំ២០២០ អាជីវកម្មដែលបានបិទទ្វារមានចំនួនប្រមាណ **៣.៦៦៤ ទីតាំង** ស្មើនឹង **៣៣,០៩%** នៃអាជីវកម្មទេសចរណ៍សរុប និងបាត់បង់ការងារផ្ទាល់ក្នុងវិស័យទេសចរណ៍ចំនួនប្រមាណ **៥៤.២៥៣ នាក់** ស្មើនឹង **៤៣,៧៣%** នៃចំនួនបុគ្គលិកសរុប។ ដោយឡែក គិតត្រឹមខែមិថុនា ឆ្នាំ២០២១ អាជីវកម្ម

ដែលបានបិទទ្វារសរុបមានប្រមាណ **៣.១៧៧ ទីតាំង** ស្មើនឹង **៣០,៦៦%** នៃអាជីវកម្មទេសចរណ៍សរុប និងប៉ះពាល់ការងារផ្ទាល់ក្នុងវិស័យទេសចរណ៍ប្រមាណ **៥០.២១៩ នាក់** ស្មើនឹង **៤០,៥២%** នៃចំនួនបុគ្គលិកសរុប។

**(១៧)** ទោះជាយ៉ាងណាក៏ដោយ កម្ពុជានៅតែជាគោលដៅដ៏ទាក់ទាញមួយសម្រាប់ភ្ញៀវទេសចរអន្តរជាតិ ដោយថ្មីៗនេះ សារព័ត៌មានអឺរ៉ូ (Euronews) ដែលជាបណ្ដាញផ្សព្វផ្សាយដ៏ធំនៅអឺរ៉ុប បានចុះផ្សាយក្នុងមាតិកា "ដំណើរកម្សាន្ត" របស់ខ្លួន ថាកម្ពុជាស្ថិតក្នុងចំណោមប្រទេស/ដែនដី ចំនួន៧ ដែលទេសចរមិនត្រូវមើលរំលងនៅពេលដែលស្ថានភាពនៃជំងឺកូវីដ-១៩ ថមថយ និងធូរស្រាល។

### ៤.៣. ការវាយតម្លៃលទ្ធភាពជោគជ័យនៃការបើកទទួលទេសចរណ៍វ៉ាក់សាំង

**(១៨)** ភាពជោគជ័យនៃការបើកទទួលទេសចរណ៍វ៉ាក់សាំង គឺអាស្រ័យលើកត្តាសំខាន់ៗ ដូចខាងក្រោម÷

**ក. កត្តាខាងក្រៅ**

**(១៩)** ទីផ្សារទេសចរណ៍ជារួមបានប្រែប្រួល ហើយនឹងមិនត្រឡប់ដូចដើមឡើយនៅក្នុងពេលដ៏ខ្លីខាងមុខ ឬលែងដូចដើមតែម្ដង។ ករណីនេះ ឥទ្ធិពលខាងក្រៅមួយចំនួនដែលជាកត្តាចូលរួមដល់ភាពជោគជ័យនៃការបើកទទួលទេសចរណ៍វ៉ាក់សាំង រួមមានដូចជា÷

**(ទី១)- និន្នាការបច្ចុប្បន្ននៃការធ្វើដំណើរចេញក្រៅប្រទេស (Outbound)÷** បន្ទាប់ពីមានការរឹតត្បិតនៃការធ្វើដំណើរឆ្លងព្រំដែនអន្តរជាតិ អស់រយៈពេលយូរ ដោយប្រទេសនីមួយៗនៅលើពិភពលោក ក្រោមហេតុផលនៃកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ បានធ្វើឱ្យតម្រូវការសម្រាប់ការធ្វើដំណើរជួបជុំគ្រួសារ, កម្សាន្ត ឬធុរកិច្ច និងអត្រានៃភ្ញៀវចេញក្រៅ (Outbound) ចាប់ផ្ដើមមានឡើងវិញ។ ទន្ទឹមនេះដែរការរឹតបន្តឹងក្នុងការធ្វើដំណើរសម្រាប់ភ្ញៀវ Outbound អាចត្រូវបានបន្ធូរបន្ថយ ឬផ្លាស់ប្ដូរជាវិជ្ជមានដោយសារការចាក់វ៉ាក់សាំងមានវឌ្ឍនភាពល្អនៅតាមបណ្ដាប្រទេសជាច្រើន និងការផ្លាស់ប្ដូរយុទ្ធសាស្ត្រពីការបិទខ្ទប់ ទៅជាការរៀនរស់ជាមួយជំងឺកូវីដ-១៩។ តាមការព្យាកររបស់អង្គការទេសចរណ៍ពិភពលោក (UNWTO) ចំនួនភ្ញៀវ Outbound នៅក្នុងឆ្នាំ ២០២១ នឹងមិនទាន់វិលត្រឡប់ទៅកាន់កម្រិតមុនវិបត្តិឡើយ។ តែទោះជាយ៉ាងណាក៏ដោយ តួលេខឆ្នាំនេះនឹងមានភាពល្អប្រសើរជាងកាលពីឆ្នាំ ២០២០ ដោយសារការកម្រើកឡើងវិញជាបណ្ដើរៗនៃចរន្តទេសចរអន្តរជាតិ។

**(ទី២)- ល្បឿននៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅលើពិភពលោក÷** គិតត្រឹមថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ បើយោងតាមអង្គការសុខភាពពិភពលោក (WHO) ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនប្រជាជននៅលើពិភពលោក មានចំនួនប្រមាណ **៦.៥៤ ប៊ីលានដូស**។ ល្បឿននៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក៏ដូចជាគោលនយោបាយបើកទេសចរណ៍ឡើងវិញប្រកបដោយសុវត្ថិភាពបានជំរុញឱ្យភ្ញៀវមានទំនោរធ្វើដំណើរចេញក្រៅឡើងវិញសម្រាប់ទីផ្សារទេសចរណ៍សំខាន់ៗមួយចំនួន។

**(ទី៣)- កត្តាចិត្តសាស្ត្រ និងចំណង់ចំណូលចិត្តរបស់ភ្ញៀវ÷** ភ្ញៀវទេសចរអន្តរជាតិពីទីផ្សារទេសចរណ៍សំខាន់ៗបានសម្របខ្លួនក្នុងស្ថានភាពគន្លងប្រក្រតីភាពថ្មី ជាមួយការអនុវត្តនូវពិធីសារ និងការណែនាំសុវត្ថិភាព និងសុខភាព ដែលមានការទទួលស្គាល់រវាងប្រទេសនិងប្រទេស។ ក្នុងន័យនេះ ភ្ញៀវទេសចរអន្តរជាតិមានទំនោរក្នុងការធ្វើដំណើរទៅទស្សនាគោលដៅទេសចរណ៍ដែលមានសុវត្ថិភាព, មានការសម្រួលដល់ការធ្វើចត្តាឡីស័ក (បន្ថយចំនួនថ្ងៃ និងរូបភាពនៃការធ្វើចត្តាឡីស័ក), ជាកញ្ចប់ទស្សនកិច្ចដែលមានការរៀបចំទុកជាមុន ផ្សារភ្ជាប់

ជាមួយផលិតផលទេសចរណ៍សុវត្ថិភាពមួយចំនួន រួមមាន អេកូទេសចរណ៍, ទេសចរណ៍បែបផ្សងព្រេង, ទេសចរណ៍ធម្មជាតិ, និងផលិតផលទេសចរណ៍មួយចំនួនទៀតដែលមិនពាក់ព័ន្ធនឹងការទាក់ទង ឬការប៉ះពាល់ដោយផ្ទាល់ច្រើន។ល។

**(ទី៤)-ការកសាងទំនុកចិត្ត និងភាពជឿជាក់សម្រាប់ភ្ញៀវទេសចរអន្តរជាតិ÷** កិច្ចសហប្រតិបត្តិការទ្វេភាគី និង/ ឬ ពហុភាគី រវាងប្រទេសនិងប្រទេស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឱ្យមានលំហូរភ្ញៀវទេសចរចេញក្រៅទៅវិញទៅមក ក្រោមរូបភាពជាកញ្ចប់ទស្សនកិច្ចរៀបចំទុកជាមុន និងមានការគ្រប់គ្រងហ្មត់ចត់ប្រកបដោយសុវត្ថិភាព ឬក្រោមរូបភាពនៃការធ្វើដំណើរទេសចរណ៍វ៉ាក់សាំងផ្សេងទៀត។

**<u>ខ. កត្តាខាងក្នុង</u>**

**(២០)** ការបើកដំណើរការទទួលទេសចរណ៍វ៉ាក់សាំងអាចប្រព្រឹត្តទៅបាន លុះត្រាតែកម្ពុជាត្រៀមខ្លួនរួចរាល់ សម្រាប់ការធានាបាននូវសុវត្ថិភាព និងសុខភាពសាធារណៈ ជូនប្រជាពលរដ្ឋ និងភ្ញៀវទេសចរ ដែលជាអាទិភាពចម្បង។ ករណីនេះ ឥទ្ធិពលខាងក្នុងមួយចំនួនដែលជាកត្តាចូលរួមដល់ភាពជោគជ័យនៃការបើកទទួលទេសចរណ៍វ៉ាក់សាំង មានដូចជា÷

**(ទី១)-ស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩នៅក្នុងផ្ទៃប្រទេស÷** ការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព បានឆ្លុះបញ្ចាំងពីសមត្ថភាពនៃការគ្រប់គ្រង និងដឹកនាំរបស់រាជរដ្ឋាភិបាលទាំងការបង្ការ, ការគ្រប់គ្រង និងការកាត់បន្ថយអត្រាចម្លងនៃជំងឺកូវីដ-១៩ តាមរយៈការដាក់ចេញនូវវិធានការត្រឹមត្រូវ និងទាន់ពេលវេលា ជាពិសេស**សសរស្តម្ភយុទ្ធសាស្ត្រទាំង** ៤ (បួន) រួមមាន÷ **១.ល្បឿនលឿននៃយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩** ទាំងដូសមូលដ្ឋាន និងដូសជំរុញ, **២.ការបង្ការ និងទប់ស្កាត់ការឆ្លង** តាមរយៈការពង្រឹងសមត្ថភាពធ្វើតេស្ត ជាពិសេសការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩, **៣.ការពង្រឹងសមត្ថភាពឆ្លើយតប និងការព្យាបាលជំងឺកូវីដ-១៩** និង **៤.ការអនុវត្តយ៉ាងម៉ឺងម៉ាត់ខ្ជាប់ខ្ជួន**នូវវិធានការសុខាភិបាល, វិធានការច្បាប់, វិធានការរដ្ឋបាល, វិធានការអប់រំ និងការកៀរគរការចូលរួមរបស់សាធារណជនគ្រប់ស្រទាប់ជាន់ថ្នាក់។

**(ទី២)-ការត្រៀមខ្លួនរបស់អាជីវកម្មទេសចរណ៍តាមគន្លងប្រក្រតីភាពថ្មី ក្នុងគ្រប់ខ្សែច្រវាក់ផលិតកម្មនៃវិស័យទេសចរណ៍÷** ទោះបីជាជំងឺកូវីដ-១៩ បានបន្ទុចបង្អាក់អាជីវកម្មទេសចរណ៍ ជាពិសេសនៅរាជធានីភ្នំពេញ, ខេត្តសៀមរាប និងខេត្តព្រះសីហនុ តែវិស័យនេះមិនបានបិទទាំងស្រុងទេ។ ក្នុងន័យនេះ ហេដ្ឋារចនាសម្ព័ន្ធ និងធនធានទេសចរណ៍ ដែលមានពីមុនវិបត្តិ ក៏ដូចជាការកសាងនូវហេដ្ឋារចនាសម្ព័ន្ធថ្មីៗ នឹងក្លាយជាមូលដ្ឋានគ្រឹះក្នុងការបើកទទួលទេសចរណ៍ឡើងវិញ។ ចំណុចគន្លឹះ គឺការកំណត់នូវពេលវេលាជាក់លាក់ និងការដាក់ចេញនិងអនុវត្តនូវវិធានការ ដើម្បីជួយសម្រួលដល់ប្រតិបត្តិករទេសចរណ៍ទាំងអស់ ឱ្យមានលទ្ធភាព និងពេលវេលាគ្រប់គ្រាន់ក្នុងការស្តារ និងរៀបចំទទួលទេសចរណ៍អន្តរជាតិឡើងវិញ។

## ៤.៤. អភិក្រមនៃការអនុវត្ត

**(២១)** ការអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង នឹងត្រូវផ្អែកតាម**អភិក្រមនៃការបើកទទួលទេសចរណ៍អន្តរជាតិឡើងវិញតាមដំណាក់កាល (Phased Approach) ជាជំហានៗ ដូចខាងក្រោម÷**

- **ជំហានទី ១ (ការចាប់ផ្តើមឡើងវិញ)** ÷ ចាប់ផ្តើមទទួលទេសចរណ៍អន្តរជាតិឡើងវិញដោយកំណត់យក**គម្រោងសាកល្បង** នៅចុងខែវិច្ឆិកា ឆ្នាំ២០២១ ដោយចាប់ផ្តើមនៅក្រុងព្រះសីហនុ និងក្រុងកោះរ៉ុងនៃខេត្តព្រះសីហនុ, និងតំបន់តារាសាគរនៃខេត្តកោះកុង, និងបន្ទាប់មកនៅខេត្តសៀមរាប នៅក្នុងខែមករា ឆ្នាំ២០២២
- **ជំហានទី ២ (ការបើកឡើងវិញតាមតំបន់)** ÷ ចាប់ផ្តើមទទួលទេសចរណ៍អន្តរជាតិមកតាមតំបន់ទេសចរណ៍សុវត្ថិភាពផ្សេងៗទៀត បន្ទាប់ពីគម្រោងសាកល្បងនៃជំហានទី ១ ទទួលបានជោគជ័យ។
- **ជំហានទី ៣ (ការបើកឡើងវិញទាំងស្រុង)** ÷ ការបើកទទួលទេសចរណ៍វ៉ាក់សាំងពេញលេញនៅទូទាំងប្រទេស។

**(២២)** ទន្ទឹមនេះដែរ ការអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង នឹងពឹងផ្អែកលើបុរេលក្ខខណ្ឌចំនួន ០៤ ÷

**(ទី១).** អត្រានៃការចាក់វ៉ាក់សាំង សំដៅបង្កើតភាពស៊ាំសហគមន៍,

**(ទី២).** អត្រានៃការឆ្លងរាលដាលជំងឺកូវីដ-១៩,

**(ទី៣).** សមត្ថភាពឆ្លើយតប និង គ្រប់គ្រងហានិភ័យដែលអាចកើតមានពីវីរុសបំប្លែងថ្មី និង

**(ទី៤).** ការត្រៀមខ្លួនរបស់ឧស្សាហកម្មទេសចរណ៍ ស្របតាម**ទស្សនទាន "IBEST"** ដោយក្នុងនោះត្រូវគិតគូរលើការពង្រឹងគុណភាពសេវាកម្ម (Improving Quality), ការរៀបចំទូវប្រព័ន្ធកក់ទុកជាមុន (Booking), ការគិតគូរអំពីបរិស្ថាន (Environment), ការគិតគូរអំពីសុវត្ថិភាពសុខភាពសាធារណៈ (Safety) និងការប្រើប្រាស់បច្ចេកវិទ្យាជាដំណោះស្រាយ (Technology) ស្របតាមគន្លងប្រក្រតីភាពថ្មី។ ទស្សនទាន **"IBEST"** គឺជាគំនិតផ្តួចផ្តើមមួយសម្រាប់ឱ្យប្រតិបត្តិករទេសចរណ៍ទាំងអស់យកទៅអនុវត្តនៅក្នុងគ្រប់កោសិកានៃខ្សែច្រវាក់ផ្គត់ផ្គង់នៃវិស័យទេសចរណ៍កម្ពុជា ពោលគឺជាគំរូអាជីវកម្មមួយ សម្រាប់ប្រតិបត្តិការផ្តល់សេវាកម្មប្រចាំថ្ងៃ សំដៅបំពេញតម្រូវការ និងឥរិយាបថថ្មីរបស់ភ្ញៀវទេសចរនៅក្នុងការធ្វើដំណើរ, វិធីសាស្ត្រថ្មីនៃការផ្សព្វផ្សាយ, បែបផែនថ្មីនៃការទំនាក់ទំនង និងការវិនិយោគបែបថ្មី ក្នុងបរិបទនៃគន្លងប្រក្រតីភាពថ្មី។

| បុរេលក្ខខណ្ឌ (លក្ខខណ្ឌចាំបាច់) | ជំហានទី ១ ការចាប់ផ្ដើមឡើងវិញ | ជំហានទី ២ ការបើកឡើងវិញតាមតំបន់ | ជំហានទី ៣ ការបើកឡើងវិញទាំងស្រុង |
|---|---|---|---|
| **(ទី១)÷ កម្រិតនៃការចាក់វ៉ាក់សាំងនៅកម្ពុជា** | បញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងដូសមូលដ្ឋាន | បញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងដូសមូលដ្ឋាន និងដូសជំរុញ (យ៉ាងហោច ៨០% នៃប្រជាជនសរុប) | បញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងដូសមូលដ្ឋាន និងដូសជំរុញ (យ៉ាងហោច ៨៥% នៃប្រជាជនសរុប) |
| **(ទី២)÷ កម្រិតនៃការចម្លងនៅកម្ពុជា[1]** | មានករណីវិជ្ជមានកូវីដ-១៩ ឆ្លងក្នុងសហគមន៍ទូទាំងប្រទេស នៅឡើយ | មានចង្កោមករណីវិជ្ជមានកូវីដ-១៩ (Clusters) នៅតាមតំបន់ភូមិសាស្ត្រមួយចំនួន | គ្មាន ឬមានករណីវិជ្ជមានកូវីដ-១៩ តិចតួច |
| **(ទី៣)÷ សមត្ថភាពឆ្លើយតប និងព្យាបាល និងការគ្រប់គ្រងហានិភ័យដែលអាចកើតមានពីវីរុសបំប្លែងថ្មី** | ការពង្រឹងសមត្ថភាពឆ្លើយតប និងព្យាបាល និងការគ្រប់គ្រងហានិភ័យ នៅតំបន់សាកល្បង | ការពង្រឹងសមត្ថភាពឆ្លើយតប និងព្យាបាល និងការគ្រប់គ្រងហានិភ័យ នៅតាមតំបន់ ឬគោលដៅសុវត្ថិភាព | ការពង្រឹងសមត្ថភាពឆ្លើយតប និងព្យាបាល និងការគ្រប់គ្រងហានិភ័យ នៅទូទាំងប្រទេស |
| **(ទី៤)÷ ការត្រៀមខ្លួនរបស់អាជីវកម្មទេសចរណ៍នៅកម្ពុជា** | សុវត្ថិភាពជាចម្បង | ទស្សនទាន "IBEST" | ទស្សនទាន "IBEST" |

**(២៣)** ជាមួយនឹងជំហាន និងបុរេលក្ខខណ្ឌខាងលើ យុទ្ធសាស្ត្រនេះនឹងអនុវត្ត ដូចខាងក្រោម÷

- ពេលវេលាជាក់ស្ដែងនៃជំហាននីមួយៗ នឹងត្រូវធ្វើការកំណត់ដោយផ្អែកលើការវាយតម្លៃជាក់ស្ដែង និងជាប់ជាប្រចាំ លើសូចនាករដែលជាបុរេលក្ខខណ្ឌ ដូចដែលបានរៀបរាប់ខាងលើ។ ជាមួយគ្នានេះ ត្រូវមានការទុកគម្លាតរយៈពេល យ៉ាងតិច ៣ (បី) ខែ ពីមួយជំហានទៅមួយជំហាន។
- ការបន្ធូរបន្ថយវិធានការសុខាភិបាលត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន និងជាជំហានៗ ទៅតាម **សេណារីយ៉ូ និងបង្គោលចរ ដោយទុកពេលវេលាគ្រប់គ្រាន់ (គម្លាតពេលវេលា)** ដើម្បីត្រួតពិនិត្យមើលវឌ្ឍនភាព ឬផលប៉ះពាល់នៃការបន្ធូរបន្ថយវិធានការទាំងនេះ នៅមុនពេលសម្រេចបន្ធូរបន្ថយវិធានការបន្ថែម។ ប៉ុន្តែប្រសិនបើមានហានិភ័យកើតឡើង ដូចជាវីរុសបំប្លែងថ្មីនៅក្នុងតំបន់បើកទទួលទេសចរណ៍វ៉ាក់សាំង ត្រូវអនុវត្ត**យុទ្ធសាស្ត្រត្រឡប់** នៅក្នុងជំហាននីមួយៗ ស្របតាមការវិវត្តជាក់ស្ដែងនៃសភាពការណ៍។

[1] កម្រិតស្ថានភាពចម្លង អាចវិវត្តន៍ក្រោយមានភាពស៊ាំសហគមន៍ និងអាចត្រូវបានវាយតម្លៃផ្អែកលើអេពីដេមីសាស្ត្រ។

- ជិហាននីមួយៗនឹងរៀបចំទៅ**តាមតំបន់ និងតាមអនុវិស័យ (សកម្មភាពទេសចរណ៍)** ដោយពិចារណាលើកម្រិតនៃអាទិភាព អត្ថប្រយោជន៍ផ្នែកសង្គម-សេដ្ឋកិច្ច លទ្ធភាពគ្រប់គ្រង និងដំណើរការ ព្រមទាំងឥទ្ធិពល/ផលប៉ះពាល់លើអនុវិស័យ និងសកម្មភាពទាំងនោះ ដោយគួរផ្តល់អាទិភាពដល់សកម្មភាពដែលជាសេវាកម្ម និងផលិតផលទេសចរណ៍ មានហានិភ័យនៃការចម្លងទាប និងមានតម្លៃបន្ថែមខ្ពស់។
- អនុវត្ត**យុទ្ធនាការផ្ញើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩** សម្រាប់មូលដ្ឋានអាជីវកម្មដែលបើកទទួលទេសចរណ៍វ៉ាក់សាំង នៅក្នុងតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ជារៀងរាល់ខែ ដោយផ្សារភ្ជាប់ជាមួយនឹងការពង្រឹងការអនុវត្តវិធានសុខាភិបាល, វិធានការរដ្ឋបាល, វិធានការច្បាប់ និងវិធានការអប់រំនានាឱ្យបានហ្មត់ចត់ នៅតាមគោលដៅទាំងនោះ។
- ភ្ញៀវទេសចរ ដែលស្ថិតនៅក្នុងកម្មវិធីទេសចរណ៍វ៉ាក់សាំងនឹងត្រូវកំណត់ដូចខាងក្រោម÷
  - ភ្ញៀវទេសចរ និងអ្នកដំណើរដែលបានចាក់វ៉ាក់សាំងគ្រប់ដូស និងដែលមកជាក្រុមតាមកញ្ចប់ទស្សនកិច្ច
  - ភ្ញៀវទេសចរ និងអ្នកដំណើរដែលបានចាក់វ៉ាក់សាំងគ្រប់ដូស និងដែលមកជាលក្ខណៈបុគ្គល ឬគ្រួសារ ឬក្រុមតូចៗ ជាទេសចរកម្រិតខ្ពស់
  - ភ្ញៀវទេសចរធុរកិច្ច និងភ្ញៀវទេសចរម៉ាយ (MICE) ដែលបានចាក់វ៉ាក់សាំងគ្រប់ដូស។

## ៥. ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ

**(២៤)** ផ្អែកលើចក្ខុវិស័យ គោលបំណង និងអភិក្រមខាងលើ យុទ្ធសាស្ត្រនឹងដាក់ចេញនូវផែនការសកម្មភាពមួយចំនួន ដែលមានភាពសមស្របសម្រាប់ការបើកទទួលភ្ញៀវទេសចរអន្តរជាតិឡើងវិញ ជាជំហានៗ ប្រកបដោយសុវត្ថិភាពខ្ពស់ ប្រកបដោយភាពជឿជាក់ រួមមានដូចខាងក្រោម÷

### ៥.១. ការកំណត់នូវប្រភពទីផ្សារទេសចរណ៍វ៉ាក់សាំង

**(២៥)** ដើម្បីបើកទទួលទេសចរណ៍វ៉ាក់សាំង ចាំបាច់ត្រូវកំណត់ទីផ្សារ និងទាក់ទាញប្រភពទីផ្សារទេសចរណ៍ដែលមានសក្តានុពល, មានហានិភ័យទាប និងមានសុវត្ថិភាព។ ទីផ្សារទេសចរណ៍សំខាន់ៗសម្រាប់កម្ពុជា ត្រូវមានការវាយតម្លៃដោយផ្អែកលើកម្រិតនៃហានិភ័យទាបពីជំងឺកូវីដ-១៩, សមត្ថភាពក្នុងការគ្រប់គ្រងស្ថានភាពកូវីដ-១៩ បានល្អ និងការផ្តល់ទំនុកចិត្ត និងភាពជឿទុកចិត្តគ្នាទៅវិញទៅមករវាងប្រទេសនិងប្រទេស។ល។ ក្នុងន័យនេះ រាជរដ្ឋាភិបាលត្រូវអនុវត្តសកម្មភាពដូចខាងក្រោម÷

**(ទី១)**- បើកទទួលភ្ញៀវទេសចរមកពីប្រភពទីផ្សារទេសចរណ៍ ដែលមានសុវត្ថិភាព និងហានិភ័យទាប។ ករណីពិនិត្យឃើញមានហានិភ័យខ្ពស់ គណៈកម្មការអន្តរក្រសួងប្រយុទ្ធប្រឆាំងជំងឺឆ្លងកូវីដ-១៩ ត្រូវលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីរឹតបន្តឹងវិធានការតាមស្ថានភាពជាក់ស្តែង។

**(ទី២)**- រៀបចំផ្តល់ទិដ្ឋាការសម្រាប់ការបើកទទួលទេសចរណ៍វ៉ាក់សាំង តាមប្រភេទទេសចរណ៍នីមួយៗ តាមជំហានៗប្រកបដោយសុវត្ថិភាព រួមមានប្រភេទទេសចរណ៍ធុរកិច្ច និងអ្នកដំណើរ, កញ្ចប់ទស្សនកិច្ច

ទេសចរណ៍ចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងប្រភេទទេសចរក្រៅពីកញ្ចប់ទស្សនកិច្ច មកជាលក្ខណៈបុគ្គល ឬជាលក្ខណៈគ្រួសារ ***(ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម)***។

| | **ដំណាក់កាលទី១** | **ដំណាក់កាលទី២** | **ដំណាក់កាលទី៣** |
|---|---|---|---|
| **តំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព** **(Safe & Green Zones/Destinations)** | • ផ្តល់ទិដ្ឋាការប្រភេទ A, B, C, E, K សម្រាប់ទេសចរ និងអ្នកដំណើរដែលបានចាក់វ៉ាក់សាំងគ្រប់ដូស<br>• បើកដំណើរការប្រភេទកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំងកូវីដ-១៩ (ទិដ្ឋាការប្រភេទ T) នៅតំបន់សាកល្បង ដោយត្រូវធ្វើចត្តាឡីស័ក **៥ថ្ងៃ** ក្រោមរូបភាពជាចត្តាឡីស័កក្នុងតំបន់<br>• ផ្តល់ទិដ្ឋាការ (ប្រភេទ T) សម្រាប់ទេសចរមកជាលក្ខណៈគ្រួសារ ឬក្រុមតូចៗ ជាទេសចរកម្រិតខ្ពស់ ដែលបានចាក់វ៉ាក់សាំងគ្រប់ដូស ដោយត្រូវធ្វើចត្តាឡីស័ក **៥ថ្ងៃ** ក្រោមរូបភាពជាចត្តាឡីស័កក្នុងតំបន់។ | • ផ្តល់ទិដ្ឋាការប្រភេទ A, B, C, E, K សម្រាប់ទេសចរ និងអ្នកដំណើរដែលបានចាក់វ៉ាក់សាំងគ្រប់ដូស<br>• បើកដំណើរការឱ្យប្រភេទកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំងកូវីដ-១៩ (ទិដ្ឋាការប្រភេទ T) តាមតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ដោយត្រូវធ្វើចត្តាឡីស័ក **៣ថ្ងៃ** ក្រោមរូបភាពជាចត្តាឡីស័កក្នុងតំបន់<br>• ផ្តល់ទិដ្ឋាការប្រភេទ T សម្រាប់ទេសចរមកជាលក្ខណៈបុគ្គល ឬជាលក្ខណៈគ្រួសារ ដែលបានចាក់វ៉ាក់សាំងគ្រប់ដូស ដោយត្រូវធ្វើចត្តាឡីស័ក **៣ថ្ងៃ** ក្រោមរូបភាពជាចត្តាឡីស័កក្នុងតំបន់។ | • ទេសចរ និងអ្នកដំណើរដែលបានចាក់វ៉ាក់សាំង មិនតម្រូវឱ្យធ្វើចត្តាឡីស័ក<br>• កញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំងកូវីដ-១៩ អាចធ្វើដំណើរទូទាំងប្រទេស ដោយមិនតម្រូវឱ្យធ្វើចត្តាឡីស័ក<br>• ទេសចរមកជាលក្ខណៈបុគ្គល ឬជាលក្ខណៈគ្រួសារដែលបានចាក់វ៉ាក់សាំង មិនតម្រូវឱ្យធ្វើចត្តាឡីស័ក។ |
| **តំបន់ផ្សេងៗ** **(Other Zones)** | • ផ្តល់ទិដ្ឋាការប្រភេទ A, B, C, E, K សម្រាប់ទេសចរ និងអ្នកដំណើរដែលបានចាក់វ៉ាក់សាំងគ្រប់ដូស<br>• បន្តព្យួរការផ្តល់ទិដ្ឋាការប្រភេទ T សម្រាប់កញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់ | • ផ្តល់ទិដ្ឋាការប្រភេទ A, B, C, E, K សម្រាប់ទេសចរ និងអ្នកដំណើរដែលបានចាក់វ៉ាក់សាំងគ្រប់ដូស<br>• ផ្តល់ទិដ្ឋាការប្រភេទ T សម្រាប់ទេសចរមកជាលក្ខណៈបុគ្គល ឬជា | |

| | | | |
|---|---|---|---|
| | វ៉ាក់សាំងកូវីដ-១៩ និងប្រភេទទេសចរមកជាលក្ខណៈបុគ្គល។ | លក្ខណៈគ្រួសារ ដោយត្រូវធ្វើចត្តាឡីស័ក **៧ថ្ងៃ** ក្នុងសណ្ឋាគារចត្តាឡីស័ក។ | |

*<u>សម្គាល់÷</u>-ចំពោះទិដ្ឋាការប្រភេទA, B, C, E, K ចំនួនថ្ងៃសម្រាប់ការធ្វើចត្តាឡីស័កជាក់ស្តែងនៅក្នុងតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព និងនៅក្នុងតំបន់ផ្សេងៗ នឹងត្រូវអនុវត្តតាមការសម្រេចដោយឡែករបស់គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩។*

*-ចំនួនថ្ងៃសម្រាប់ការធ្វើចត្តាឡីស័កអាចនឹងមានការកំណត់ដោយឡែក តាមការវិវត្តជាក់ស្តែងនៃស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។*

**(ទី៣)**-លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី ជាមួយបណ្តាប្រទេសដែលជាប្រភពទីផ្សារទេសចរណ៍សំខាន់ៗរបស់កម្ពុជា ក្នុងការសហការរៀបចំទទួលទេសចរណ៍វ៉ាក់សាំង ពិសេសក្នុងការចែករំលែកព័ត៌មាន, ការទទួលស្គាល់គ្នាទៅវិញទៅមកក្នុងការអនុវត្តវិធានសុវត្ថិភាពប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, ការសម្រួលការធ្វើដំណើរទេសចរណ៍ និងការកាត់បន្ថយរបាំងរបស់រដ្ឋាភិបាល (ដូចជា លក្ខខណ្ឌនៃការធ្វើចត្តាឡីស័ក...) ស្របតាមស្ថានការណ៍ជាក់ស្តែង។ កិច្ចសហប្រតិបត្តិការអន្តរជាតិពិតជាមានសារៈសំខាន់ណាស់ សម្រាប់ការបង្កើនទំនុកចិត្ត និងភាពជឿជាក់គ្នាទៅវិញទៅមក រវាងប្រភពទីផ្សារ និងគោលដៅកម្ពុជា ដូចដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់កាលពីពេលថ្មីៗនេះថា "**ដរាបណាប្រទេសដទៃមិនទាន់មានសុវត្ថិភាព កម្ពុជាក៏មិនទាន់មានសុវត្ថិភាពដែរ**" ពោលគឺឱកាសនៃការចម្លង និងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅមានគ្រប់ពេល។

**(ទី៤)**-ប្រើប្រាស់វិធីសាស្ត្រផ្អែកលើតម្រូវការ ដោយផ្អែកលើការស្រាវជ្រាវឱ្យបានស៊ីជម្រៅទាក់ទងនឹងទីផ្សារ និងប្រភេទនៃការធ្វើដំណើររបស់ទីផ្សារសំខាន់ៗ ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង ព្រមទាំងការយល់ដឹងកាន់តែប្រសើរពីតម្រូវការសម្រាប់ការទស្សនានៃភ្ញៀវទេសចរអន្តរជាតិមកកម្ពុជា។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងផ្តល់ការលើកទឹកចិត្តទាក់ទាញភ្ញៀវទេសចរអន្តរជាតិដែលមកស្នាក់នៅរយៈពេលយូរ និងភ្ញៀវទេសចរមកម្តងហើយម្តងទៀត តាមរយៈ÷ **១).** បង្កើតគោលនយោបាយ **"ទិដ្ឋាការទេសចរណ៍ពិសេស"** និង **២).** ជំរុញភាពទាក់ទាញឱ្យទេសចរស្នាក់នៅរយៈពេលយូរ តាមរយៈការធានាបាននូវសុវត្ថិភាព និងកត្តាថ្លៃប្រកួតប្រជែង ជាដើម ដោយភ្ញៀវទេសចរមិនចង់ផ្លាស់ទីច្រើនកន្លែងនៅអំឡុងពេលធ្វើដំណើរ តាមគន្លងប្រក្រតីភាពថ្មី។

**(ទី៥)**-ពង្រឹងសកម្មភាពរបស់**ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា** ដោយប្រែក្លាយជាគ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច។

### ៥.២. ការគ្រប់គ្រងទេសចរមុនពេលចេញដំណើរ និងពេលមកដល់អាកាសយានដ្ឋានអន្តរជាតិ

**(២៦)** អ្នកដំណើរ និងភ្ញៀវទេសចរនៅតាមច្រកទ្វារអន្តរជាតិ ចេញនិងចូលមានលក្ខណៈជាបណ្តុំ និងមានចំនួនច្រើន ដែលបង្កនូវហានិភ័យក្នុងការឆ្លងរាលដាលនៃជំងឺឆ្លងខ្ពស់។ ដោយឈរលើកត្តានេះ ផែនការ

យុទ្ធសាស្ត្រដាក់ចេញយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងការមកដល់នៃភ្ញៀវទេសចរ និងអ្នកដំណើរដែលបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩គ្រប់ដូស ដោយគិតចាប់ពីមុនពេលមកដល់, ពេលមកដល់ច្រកទ្វារអន្តរជាតិ និងការស្នាក់នៅក្នុងសណ្ឋាគារ ដូចខាងក្រោម÷

**ក. ផែនការសកម្មភាពសម្រាប់មុនពេលទេសចរចូលមកកម្ពុជា**÷ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម÷

- បង្កើតប្រព័ន្ធស្នើសុំ**លិខិតអនុញ្ញាតចូលប្រទេសកម្ពុជា** ក្រោមឈ្មោះថា **"Safe Travel Pass"** ជាផ្លូវការ សម្រាប់អ្នកដំណើរ និងភ្ញៀវទេសចរ លើកលែងតែភ្ញៀវដែលស្នើសុំទិដ្ឋាការប្រភេទការទូត (ប្រភេទ A) ផ្លូវការ (ប្រភេទ B) បោរីភាព (ប្រភេទ C) និងទិដ្ឋាការវិនិយោគ (ប្រភេទ E) រួមជាមួយការបញ្ជាក់ពីការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩គ្រប់ដូស (Vaccination Passport or Digital Health Pass) ដោយផ្សារភ្ជាប់ជាមួយនីតិវិធីស្នើសុំទិដ្ឋាការ ដែលមានស្រាប់ ***(នីតិវិធីលម្អិតដូចមានក្នុងឧបសម្ព័ន្ធទី២)***។ ប្រព័ន្ធស្នើសុំលិខិតអនុញ្ញាតនេះ គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រងស្ថានការណ៍ ពិសេសសម្រាប់ការអនុវត្ត **"ការបើក-ការបិទ"** នៅក្នុងជំហាននីមួយៗនៃផែនការយុទ្ធសាស្ត្រ ទៅតាមការវិវត្តជាក់ស្តែងនៃសភាពការណ៍។
- ភ្ញៀវទេសចរត្រូវទិញធានារ៉ាប់រងសុខភាព សម្រាប់ការធ្វើដំណើរមកកម្ពុជា រួមបញ្ចូលទាំងការធានារ៉ាប់រងសម្រាប់ការព្យាបាលជំងឺកូវីដ-១៩ ជាយថាហេតុ និងសំណងលើការលុបចោលការកក់សេវាកម្មទេសចរណ៍នានានៅប្រទេសកម្ពុជា ជាយថាហេតុ។
- រៀបចំបង្កើត**ថ្នាលឌីជីថល**ផ្លូវការមួយសម្រាប់អ្នកដំណើរ និងភ្ញៀវទេសចរ ធ្វើការស្នើសុំកន្លែងសម្រាប់ការធ្វើចត្តាឡីស័កជាមុន (ចំពោះអ្នកដំណើរ និងភ្ញៀវទេសចរដែលមកក្នុងគោលដៅផ្សេង ក្រៅពីតំបន់ឬគោលដៅទេសចរណ៍សុវត្ថិភាព) មុនពេលមកប្រទេសកម្ពុជា។
- ជនបរទេសដែលជាអ្នកដំណើរ និងភ្ញៀវទេសចរអន្តរជាតិទាំងអស់ចាំបាច់ត្រូវស្នើសុំទិដ្ឋាការមុនចូលមកកម្ពុជា ដោយអាចធ្វើឡើងតាមរយៈវិធី **២ (ពីរ) យ៉ាង** គឺ÷ **១).** ការស្នើសុំដោយផ្ទាល់នៅតាមបណ្តាស្ថានទូត និងស្ថានកុងស៊ុលរបស់កម្ពុជាប្រចាំនៅបរទេស និង ២). ការស្នើសុំទិដ្ឋាការអេឡិចត្រូនិច (E-Visa) តែនៅបន្តផ្អាកការផ្តល់ទិដ្ឋាការពេលមកដល់។
- នីតិវិធីនៃការបើកទទួលទេសចរណ៍វ៉ាក់សាំងនេះ គឺអនុវត្តតែចំពោះភ្ញៀវទេសចរ និងអ្នកដំណើរអន្តរជាតិ ដែលចូលមកកម្ពុជា តាមផ្លូវអាកាសប៉ុណ្ណោះ នាពេលចាប់ផ្តើម។ ការទទួលទេសចរធ្វើដំណើរមកកម្ពុជាតាមច្រកផ្សេងទៀតនឹងត្រូវគិតគូរក្នុងជំហានទី២ ស្របតាមការវិវត្តជាក់ស្តែងនៃស្ថានភាពជំងឺកូវីដ-១៩។

**ខ. ផែនការសកម្មភាពគ្រប់គ្រងការធ្វើដំណើរតាមផ្លូវអាកាសប្រកបដោយសុវត្ថិភាព**÷ ដើម្បីពង្រឹងការធ្វើដំណើរតាមផ្លូវអាកាសប្រកបដោយសុវត្ថិភាព, ក្រុមហ៊ុនអាកាសចរណ៍ទាំងអស់ត្រូវចូលរួមអនុវត្តសកម្មភាពដូចខាងក្រោម÷

- គាំទ្រដល់កិច្ចដំណើរការនៃការបើកទទួលទេសចរណ៍វ៉ាក់សាំង ដោយត្រូវគោរពតាម **"នីតិវិធីប្រតិបត្តិស្តង់ដា (SOP) តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ក្រុមហ៊ុនអាកាសចរណ៍"** ដែលរៀបចំដោយក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ។
- តម្រូវឱ្យបុគ្គលិកបម្រើការងារទាំងអស់ទទួលបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩។
- ទិញស្តុកឧបករណ៍ និងធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់បុគ្គលិករបស់ខ្លួនក្នុងកម្រិតណាមួយ ដោយផ្តល់អាទិភាពដល់បុគ្គលិកដែលមានរោគសញ្ញា, ទើបត្រឡប់មកពីបរទេស ឬ មានទំនាក់ទំនងញឹកញាប់ផ្ទាល់ជាមួយអតិថិជន។ល។
- លើកទឹកចិត្តការប្រើប្រាស់បច្ចេកវិទ្យាដែលមានសុវត្ថិភាព រហ័ស និងប៉ះពាល់តិចតួច។

**គ. ផែនការសកម្មភាពគ្រប់គ្រងការមកដល់នៅអាកាសយានដ្ឋានអន្តរជាតិ**

ការគ្រប់គ្រងការមកដល់របស់ភ្ញៀវទេសចរនៅតាមអាកាសយានដ្ឋានអន្តរជាតិជាចំណុចសំខាន់ដែលត្រូវថ្លឹងថ្លែងរវាងទិដ្ឋភាពនៃការគ្រប់គ្រងការឆ្លងរាលដាលជំងឺកូវីដ-១៩ និងការផ្តល់ភាពងាយស្រួលដល់អ្នកទេសចរ។ ក្នុងន័យនេះ សកម្មភាពមួយចំនួននឹងត្រូវអនុវត្ត ដូចខាងក្រោម÷

- អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវ **"នីតិវិធីប្រតិបត្តិស្តង់ដា (SOP) តាមគន្លងប្រក្រតីភាពថ្មីសម្រាប់អាកាសយានដ្ឋាន និងច្រកទ្វារអន្តរជាតិ"** ដែលត្រូវរៀបចំដោយក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ រួមទាំងនីតិវិធីសម្រួលពិសេសដោយឡែកសម្រាប់ភ្ញៀវទេសចរនៅក្នុងកម្មវិធីទេសចរណ៍វ៉ាក់សាំង។
- បញ្ជូលតួនាទី និងភារកិច្ចរបស់មន្ត្រីសុខាភិបាលក្នុងការវាយតម្លៃហានិភ័យសុខភាពរបស់អ្នកដំណើរ និងភ្ញៀវទេសចរ នៅក្នុងយន្តការត្រួតពិនិត្យនៅតាមច្រកទ្វារអន្តរជាតិ ដែលមានស្រាប់។
- **ចំពោះភ្ញៀវទេសចរស្ថិតនៅក្នុងកម្មវិធីទេសចរណ៍វ៉ាក់សាំង នឹងត្រូវទទួលបាននូវការធ្វើតេស្តរកវីរុសកូវីដ-១៩** តាមរយៈការប្រើប្រាស់ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នៅច្រកទ្វារអន្តរជាតិ។
  - ករណីបុគ្គលទទួលលទ្ធផលវិជ្ជមានកូវីដ-១៩ ដោយឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ បុគ្គលនោះត្រូវដាក់ឱ្យនៅដាច់ដោយឡែក ដើម្បីទទួលការធ្វើតេស្ត PCR បញ្ជាក់បន្ថែមទៀត ដើម្បីចៀសវាងលទ្ធផលវិជ្ជមានដោយភាន់ច្រឡំ (False Positive) មុននឹងបញ្ជូនទៅធ្វើការព្យាបាល តាមនីតិវិធីជាធរមាន។ ដោយឡែកភ្ញៀវទេសចរ និងអ្នករួមដំណើរតាមជើងយន្តហោះជាមួយបុគ្គលវិជ្ជមានកូវីដ-១៩ ត្រូវដាក់ឱ្យនៅដាច់ដោយឡែក ដើម្បីទទួលការធ្វើតេស្ត PCR បញ្ជាក់បន្ថែមទៀត ទាំងអស់គ្នា ដោយរាល់ការចំណាយគឺជាបន្ទុករបស់ភ្ញៀវ និងអ្នកដំណើរ ដោយប្រើប្រាស់ការធានារ៉ាប់រង។
  - ករណីលទ្ធផលអវិជ្ជមាន ភ្ញៀវទេសចរ និងអ្នកដំណើរ អាចធ្វើដំណើរទៅកន្លែងស្នាក់នៅដែលបានកក់ទុកជាមុន ហើយតម្រូវឱ្យមានការធ្វើតេស្ត PCR ចំនួន ១ដងទៀត នៅទីតាំង

ស្នាក់នៅ នៅថ្ងៃទី៤ នៃការមកដល់ សម្រាប់ការអនុវត្តជំហានទី១ និងនៅថ្ងៃទី២ នៃការមកដល់ សម្រាប់ការអនុវត្តជំហានទី២។

- **ចំពោះភ្ញៀវទេសចរ និងអ្នកដំណើរ ដែលមកក្នុងតំបន់ផ្សេង ក្រៅពីតំបន់ឬគោលដៅទេសចរណ៍សុវត្ថិភាព ត្រូវអនុវត្តតាមនីតិវិធី ដែលបានដាក់ចេញដោយក្រសួងសុខាភិបាល។**
- អាជ្ញាធរមានសមត្ថកិច្ចដែលនៅជួរមុខតាមច្រកទ្វារអន្តរជាតិទាំងអស់ រួមមាន នគរបាលព្រំដែន, នគរបាលអន្តោប្រវេសន៍, មន្ត្រីគយ, កងកម្លាំងប្រដាប់អាវុធ, មន្ត្រីសុខាភិបាល និងមន្ត្រីមូលដ្ឋាន ត្រូវយល់ដឹងអំពី **"គន្លងប្រក្រតីភាពថ្មី"** ដោយយកចិត្តទុកដាក់ជាប្រចាំនូវការរក្សាគម្លាតសុវត្ថិភាព ពាក់ម៉ាសការពារ រក្សាអនាម័យ លាងដៃនឹងសាប៊ូ អាកុល ឬជែល និងប្រុងប្រយ័ត្នការឆ្លងពីអ្នកដំណើរ និងភ្ញៀវទេសចរដែលចេញ-ចូលតាមច្រកទ្វារអន្តរជាតិ។
- រៀបចំសៀវភៅណែនាំដល់អ្នកដំណើរ និងភ្ញៀវទេសចរ អំពី **"ប្រការគួរធ្វើ និងមិនគួរធ្វើ" (Do & Don't)** នៅតាមច្រកទ្វារអន្តរជាតិ និងផ្តល់ព័ត៌មានងាយស្រួលស្វែងរក អំពីនីតិវិធីប្រតិបត្តិស្តង់ដា (SOP), វិធានសុវត្ថិភាពទេសចរណ៍, វិធានសុខាភិបាល។ល។
- បង្កើនការប្រើប្រាស់បច្ចេកវិទ្យានៅតាមច្រកទ្វារអន្តរជាតិប្រកបដោយសុវត្ថិភាព រហ័ស និងប៉ះពាល់តិចតួច។

**ឃ. ផែនការសកម្មភាពគ្រប់គ្រងការធ្វើចត្តាឡីស័ក និងនីតិវិធីសម្របសម្រួលនានា÷** អាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកទ្វារអន្តរជាតិទាំងអស់ត្រូវអនុវត្តសកម្មភាពដូចខាងក្រោម÷

- រៀបចំយន្តការគ្រប់គ្រង និងសម្រួលដល់អ្នកដំណើរ និងភ្ញៀវទេសចរពីអាកាសយានដ្ឋានទៅកាន់គោលដៅសម្រាប់ការធ្វើចត្តាឡីស័កឱ្យបានហ្មត់ចត់ និងប្រកបដោយសុវត្ថិភាព សម្រាប់អ្នកដែលត្រូវធ្វើចត្តាឡីស័កនៅក្នុងតំបន់ឬគោលដៅទេសចរណ៍សុវត្ថិភាព។
- អនុវត្តវិធានការចត្តាឡីស័កសម្រាប់អ្នកដំណើរ និងភ្ញៀវទេសចរឱ្យបានហ្មត់ចត់ ស្របតាមជំហាន និងតំបន់គោលដៅទេសចរណ៍សុវត្ថិភាព ដូចដែលបានរៀបរាប់ខាងលើ ដើម្បីធានាមិនឱ្យមានការគេចវេសពីការធ្វើចត្តាឡីស័ក និងការចល័តភ្ញៀវទៅកាន់តំបន់ផ្សេងៗ។

### ៥.៣. ការត្រៀមលក្ខណៈសម្បត្តិនៃខ្សែសង្វាក់ទេសចរណ៍ស្របតាមគន្លងប្រក្រតីភាពថ្មី

**(២៧)** ការធានាបាននូវទំនុកចិត្ត និងភាពជឿជាក់ក្នុងគ្រប់ខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងវិស័យទេសចរណ៍ គឺជាចំណុចគន្លឹះអាទិភាព ដោយត្រូវគិតពី**ដើមខ្សែដល់ចុងខ្សែ** និងដោយគិតចាប់ពីពេលចេញពីអាកាសយានដ្ឋាននៃប្រទេសប្រភពទីផ្សារ រហូតដល់ពេលមកដល់ ពេលស្នាក់នៅកម្ពុជា និងពេលត្រឡប់ទៅប្រទេសដើមវិញ។ ក្នុងន័យនេះ ការបើកទទួលទេសចរណ៍វ៉ាក់សាំង នឹងផ្តល់សេវាកម្មទេសចរណ៍ប្រកបដោយសុវត្ថិភាព នៅគ្រប់ខ្សែច្រវាក់តម្លៃនីមួយៗ ដែលមានសកម្មភាពដូចខាងក្រោម÷

-រៀបចំ **"ពិធីសារស្ដីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង"** ដោយត្រូវគិតពីដើមខ្សែដល់ចុងខ្សែ រាប់គិតចាប់ពីពេលចេញពីព្រលានយន្តហោះនៃប្រទេសប្រភពទីផ្សារ រហូតដល់ពេលមកដល់ ពេលស្នាក់នៅកម្ពុជា និងពេលត្រឡប់ទៅប្រទេសដើមវិញ។

-ម្ចាស់អាជីវកម្មទេសចរណ៍ ត្រូវឱ្យបុគ្គលិករបស់ខ្លួនចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពជំនាញ (Reskilling) និងការបង្កើនចំណេះដឹងបន្ថែម (Upskilling) ជាពិសេស ការបណ្ដុះបណ្ដាលបន្ថែមនូវជំនាញឌីជីថល ដែលរៀបចំឡើងដោយក្រសួងទេសចរណ៍ និង/ឬសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍។

-សិក្សារៀបចំ និងបន្តដាក់ចេញវិធានការទ្រទ្រង់ថ្មីៗ ផ្នែកសេដ្ឋកិច្ច ដល់ឧស្សាហកម្មទេសចរណ៍ និងការធ្វើការកែទម្រង់ស៊ីជម្រៅចំពោះវិស័យទេសចរណ៍កម្ពុជា ស្របតាមជំហាននៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ និងការវិវត្តជាក់ស្ដែងនៃសភាពការណ៍វិបត្តិនៃជំងឺកូវីដ-១៩ ពិសេសដាក់ចេញយន្តការហិរញ្ញប្បទានសម្រាប់ដំណើរការអាជីវកម្មទេសចរណ៍ឡើងវិញសម្រាប់ដំណើរការសាកល្បងនៃគម្រោងបើកទទួលទេសចរណ៍វ៉ាក់សាំង។

-ការីទេសចរណ៍ត្រូវចូលរួមបញ្ចូលទិន្នន័យក្នុង **"ប្រព័ន្ធកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩"** ***(នីតិវិធីលម្អិតដូចមានក្នុងឧបសម្ព័ន្ធទី៣)*** និងរៀបចំគ្រប់ដំណើរកម្សាន្តនីមួយៗឱ្យស្ថិតក្រោមការគ្រប់គ្រងច្បាស់លាស់ មានហានិភ័យទាប និងប្រកបដោយសុវត្ថិភាព។ ប្រព័ន្ធគ្រប់គ្រងការីទេសចរណ៍នេះ គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រងសភាពការណ៍ ជាក់ស្ដែងនៃការបើកទទួលកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ពិសេសសម្រាប់ការអនុវត្ត **"ការបើក-ការបិទ"** នៅក្នុងជំហាននីមួយៗនៃផែនការយុទ្ធសាស្ត្រ។

-ជំរុញការរៀបចំសេវាកម្មសុវត្ថិភាព តាមរយៈ÷ **១).** រៀបចំឱ្យប្រព័ន្ធអាចកក់ទុកជាមុន (Book-in-advance System) និងអាចកក់សេវាកម្មបន្ទាប់បន្សំផ្សេងទៀតក្នុងកញ្ចប់តែមួយ (All-in-one Package) ដែលស្ថិតក្រោមការគ្រប់គ្រង និងមានសុវត្ថិភាពដល់ភ្ញៀវទេសចរ, **២).** ផ្អាកការបម្រើអាហារប៊ូហ្វេសម្រាប់អ្នកចូលរួម ដោយប្ដូរទៅជាអាហារកុម្ម៉ង់សម្រាប់ភ្ញៀវម្នាក់ៗ ឬអាហារវេចខ្ចប់ទុកជាមុន, **៣).** ការទូទាត់ប្រាក់ដោយមិនប្រើប្រាស់សាច់ប្រាក់ សេវាកម្មវេចខ្ចប់ និងដឹកជញ្ជូនដល់កន្លែងស្នាក់នៅ និង **៤).** លើកទឹកចិត្តការប្រើប្រាស់បច្ចេកវិទ្យាដែលមានសុវត្ថិភាព រហ័ស និងប៉ះពាល់តិចតួច។ល។

-ប្រតិបត្តិករទេសចរណ៍ទាំងអស់តម្រូវឱ្យបុគ្គលិកខ្លួនទទួលបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ គ្រប់ដូស និងទិញស្តុកឧបករណ៍ធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់បុគ្គលិក ព្រមទាំងបញ្ចូលទិន្នន័យបុគ្គលិកដែលបានចាក់វ៉ាក់សាំងទៅក្នុង **ប្រព័ន្ធ Telegram BOT** ***(ដូចមានក្នុងឧបសម្ព័ន្ធទី៤)***។ ទន្ទឹមនេះ ត្រូវរៀបចំបង្កើត **ឡាបិល "VACCINATED" នៅតាមមូលដ្ឋានអាជីវកម្ម**

**ទេសចរណ៍ទាំងអស់** ដើម្បីផ្សព្វផ្សាយ និងបញ្ជាក់ថាបុគ្គលិកបម្រើការងារក្នុងនោះបានទទួលការចាក់វ៉ាក់សាំង រួចរាល់ ***(ដូចមានក្នុងឧបសម្ព័ន្ធទី៥)*** ឬបុគ្គលិកបម្រើការទាំងអស់ត្រូវពាក់ប័ណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅពេលបំពេញការងារ។

-គ្រប់អាជីវកម្មទេសចរណ៍ដែលធ្លាប់ទទួលបានឡាបិល **"វិធានសុវត្ថិភាពទេសចរណ៍"** ទាំងអស់ ត្រូវធ្វើកិច្ចសន្យាអនុវត្ត និងទទួលការវាយតម្លៃដោយចៃដន្យ ពីក្រសួងទេសចរណ៍តាមការចាំបាច់ សំដៅពង្រឹងប្រសិទ្ធភាព ការតាមដាន ចូលរួមគាំទ្រដល់កិច្ចដំណើរការនៃការបើកទទួលទេសចរណ៍វ៉ាក់សាំង។

-រៀបចំបង្កើត **"កម្មវិធីតាមដានដំណើរកម្សាន្តរបស់ភ្ញៀវ" (Tracerapp)** សម្រាប់ភ្ញៀវទេសចរអន្តរជាតិ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបង្ការ និងចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ដោយភ្ញៀវទេសចរត្រូវប្រើប្រាស់កម្មវិធីនេះនៅក្នុងទូរស័ព្ទដៃ នៅពេលមកដល់ប្រទេសកម្ពុជា ដើម្បីធ្វើការកត់ត្រាពីទីកន្លែងដែលភ្ញៀវបានទៅ និងករណីដែលភ្ញៀវទេសចរបានពាក់ព័ន្ធនឹងការឆ្លងជំងឺកូវីដ-១៩។

### ៥.៤. ការកំណត់ និងគ្រប់គ្រងគោលដៅទេសចរណ៍សុវត្ថិភាព

**(២៨)** ក្នុងដំណាក់កាលនៃរស់នៅជាមួយកូវីដ-១៩ ការកំណត់នូវតំបន់ ដែលមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ការបើកទទួលភ្ញៀវទេសចរអន្តរជាតិជាចំណុចសំខាន់។ ក្នុងន័យនេះ យុទ្ធសាស្ត្រនេះនឹងអនុវត្តនូវសកម្មភាពចាំបាច់មួយចំនួន ដូចខាងក្រោម÷

-សិក្សាកំណត់តំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ដោយឈរលើសូចនាករសមិទ្ធកម្ម÷ **១).** អត្រានៃការចាក់វ៉ាក់សាំង សំដៅបង្កើតភាពស៊ាំសហគមន៍, **២).** អត្រាអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និងកម្រិតធ្ងន់ និងអត្រាស្លាប់នៃអ្នកជំងឺកូវីដ-១៩, **៣).** សមត្ថភាពឆ្លើយតប និងព្យាបាល និងការគ្រប់គ្រងហានិភ័យដែលអាចកើតមានពីវីរុសបំប្លែងថ្មី និង **៤).** ការត្រៀមខ្លួនរបស់ឧស្សាហកម្មទេសចរណ៍។ ការកំណត់សូចនាករសមិទ្ធកម្មនេះគឺជាគន្លឹះយុទ្ធសាស្ត្រសម្រាប់ភាពជោគជ័យនៃការបើកទទួលទេសចរណ៍វ៉ាក់សាំង ដែលតម្រូវឱ្យមានការគិតគូរគ្រប់ជ្រុងជ្រោយ ដូចដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់កាលពីពេលថ្មីៗនេះថា "**វ៉ាក់សាំងតែមួយមុខមិនគ្រប់ទេ ចាំបាច់ត្រូវបន្តជំរុញការអនុវត្តវិធានសុខាភិបាល និងវិធានសុវត្ថិភាពឱ្យបានខ្ជាប់ខ្ជួន**"។ ផ្អែកលើការគណនាសន្ទស្សន៍ខាងក្រោម យើងអាចកំណត់បានកម្រិតហានិភ័យនៃតំបន់ឬគោលដៅ សម្រាប់ការបើកទទួលទេសចរណ៍វ៉ាក់សាំង÷

| វិធីសាស្ត្រជ្រើសរើសតំបន់ឬគោលដៅសម្រាប់បើកទទួលទេសចរណ៍វ៉ាក់សាំង | | |
|---|---|---|
| **សូចនាករសមិទ្ធកម្ម (វង្វាស់ពិដាន)** | **អត្រានៃការចាក់វ៉ាក់សាំង** | **យ៉ាងតិច ៨០%*** |
| | **អត្រាអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និងកម្រិត** | -អត្រាអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យមនិងកម្រិតធ្ងន់ចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ មណ្ឌលព្យាបាល (ចំនួនករណីថ្មី) ក្នុង |

| | | |
|---|---|---|
| | **ធ្ងន់ និងអត្រាស្លាប់នៃអ្នកជំងឺកូវីដ-១៩** | ចំណោមប្រជាជន ១០០.០០០នាក់<br>ក្នុងរយៈពេល២សប្តាហ៍ចុងក្រោយ ≤ **១០ ករណី ****<br>-អត្រាស្លាប់នៃអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និងកម្រិតធ្ងន់សម្រាកនៅមន្ទីរពេទ្យ មណ្ឌលព្យាបាល ក្នុងចំណោមអ្នកជំងឺកូវីដ-១៩ថ្មី កម្រិតមធ្យម និងកម្រិតធ្ងន់សម្រាកព្យាបាលនៅមន្ទីរពេទ្យ មណ្ឌលព្យាបាល ក្នុងរយៈពេល២សប្តាហ៍ចុងក្រោយ<br>≤ **១0% ***** |
| | **សមត្ថភាពឆ្លើយតប និងព្យាបាល និងការគ្រប់គ្រងហានិភ័យដែលអាចកើតមានពីវីរុសបំប្លែងថ្មី** | -មានសមត្ថភាពតាមដាន, រុករកឃើញឆាប់, គ្រប់គ្រងបានលឿន និងកាត់ផ្តាច់ការឆ្លងរាលដាលបានរហ័ស<br>-មានមន្ទីរពេទ្យ, មន្ទីរពេទ្យបង្អែក, មណ្ឌលសុខភាព, មណ្ឌលព្យាបាល, មន្ទីរ/បន្ទប់ពិសោធន៍, សំភារៈបរិក្ខារ, គ្រូពេទ្យ និងបុគ្គលិកសុខាភិបាល គ្រប់គ្រាន់ |
| | **ការត្រៀមលក្ខណៈនៃឧស្សាហកម្មទេសចរណ៍** | -មាន **៧៥%****** នៃអាជីវកម្មទេសចរណ៍កំពុងដំណើរការទទួលបានឡាបិលវិធានសុវត្ថិភាពទេសចរណ៍ និង<br>-មាន **១00%******* នៃបុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ដែលបានចាក់វ៉ាក់សាំងគ្រប់ដូស |

***រូបមន្តគណនា៖***

$$*\text{អត្រានៃការចាក់វ៉ាក់សាំង} = \frac{\text{ចំនួនអ្នកចាក់វ៉ាក់សាំងគ្រប់ដូសមូលដ្ឋាន}}{\text{ចំនួនប្រជាជនសរុប}} \times ១០០$$

****** អត្រាអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យមនិងកម្រិតធ្ងន់ចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ មណ្ឌលព្យាបាល (ចំនួនករណីថ្មី) ក្នុងចំណោមប្រជាជន ១០០.០០០នាក់ ក្នុងរយៈពេល ២សប្តាហ៍ចុងក្រោយ =

$$\frac{\text{ចំនួនអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និងកម្រិតធ្ងន់ចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ មណ្ឌលព្យាបាល (ចំនួនករណីថ្មី) ក្នុងរយៈពេល២សប្តាហ៍ចុងក្រោយ}}{\text{ចំនួនប្រជាជនសរុប}} \times ១០០០០០$$

******* អត្រាស្លាប់នៃអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និងកម្រិតធ្ងន់សម្រាកនៅមន្ទីរពេទ្យ មណ្ឌលព្យាបាល ក្នុងចំណោមអ្នកជំងឺកូវីដ-១៩ថ្មី កម្រិតមធ្យម និងកម្រិតធ្ងន់សម្រាកព្យាបាលនៅមន្ទីរពេទ្យ មណ្ឌលព្យាបាល ក្នុងរយៈពេល២សប្តាហ៍ចុងក្រោយ =

$$\frac{\text{ចំនួនករណីស្លាប់នៃអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និងកម្រិតធ្ងន់សម្រាកព្យាបាល នៅមន្ទីរពេទ្យ មណ្ឌលព្យាបាល (រដ្ឋ និង ឯកជន) ក្នុងរយៈពេល ២សប្តាហ៍ចុងក្រោយ}}{\text{ចំនួនអ្នកជំងឺកូវីដ-១៩ ថ្មី កម្រិតមធ្យម និងកម្រិតធ្ងន់ដែលបានបញ្ជូនចូលជាលើកដំបូង សម្រាកព្យាបាលនៅមន្ទីរពេទ្យ មណ្ឌលព្យាបាល (រដ្ឋ និង ឯកជន) ក្នុងរយៈពេល ២សប្តាហ៍ចុងក្រោយ}} \times ១០០$$

$$****\text{ភាគរយនៃអាជីវកម្មសុវត្ថិភាព} = \frac{\text{ចំនួនអាជីវកម្មទទួលបានឡាបិលវិធានសុវត្ថិភាពទេសចរណ៍}}{\text{ចំនួនអាជីវកម្មកំពុងដំណើរការសរុប}} \times ១០០$$

*****ភាគរយនៃបុគ្គលិកបានចាក់វ៉ាក់សាំង = $\frac{\text{បុគ្គលិកក្នុងវិស័យទេសចរណ៍ដែលបានចាក់វ៉ាក់សាំងគ្រប់ដូស}}{\text{ចំនួនបុគ្គលិកកំពុងបម្រើការងារសរុប}} \times ១០០$

*-សូចនាករសមិទ្ធកម្មសម្រាប់ការកំណត់តំបន់ឬគោលដៅទេសចរណ៍សុវត្ថិភាព នឹងមានការប្រែប្រួលតាមការវិវត្តជាក់ស្តែងនៃស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។*

*-ការកំណត់តំបន់ ឬគោលដៅសម្រាប់ការបើកទទួលទេសចរណ៍វ៉ាក់សាំង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩។*

**(២៩)** មូលដ្ឋានអាជីវកម្មដែលបើកទទួលទេសចរណ៍វ៉ាក់សាំង នៅក្នុងតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាពត្រូវមានការដាក់ចេញ**យុទ្ធនាការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩** ដល់បុគ្គលិកគ្រប់រូបនៅក្នុងមូលដ្ឋានអាជីវកម្ម ឱ្យបានយ៉ាងតិចណាស់មួយខែម្តង ផ្សារភ្ជាប់ជាមួយការពង្រឹងវិធានសុខាភិបាល, វិធានការរដ្ឋបាល, វិធានការច្បាប់ និងវិធានការអប់រំនានាឱ្យបានហ្មត់ចត់ នៅតាមគោលដៅទាំងនោះ។ ការអនុវត្តនេះគឺឈរលើស្មារតីប្រាកដនិយម ហើយនឹងត្រូវប្រើប្រាស់ជារូបភាពផ្សព្វផ្សាយសាធារណៈ សម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរគោលដៅផងដែរ។

-រៀបចំគោលដៅទេសចរណ៍សុវត្ថិភាព ដោយត្រូវគិតគូរឱ្យបានហ្មត់ចត់លើហានិភ័យនៃការចម្លងរបស់អ្នកដំណើរ និងភ្ញៀវទេសចរ ក្នុងនោះមាន÷ **១).** ការប្រើប្រាស់បច្ចេកវិទ្យា, **២).** ការបណ្តុះបណ្តាលដល់មន្ត្រីមូលដ្ឋាន និងប្រជាពលរដ្ឋ និង **៣).** សមត្ថភាពផ្នែកសុខាភិបាល ដូចជាមានមន្ត្រីសុខាភិបាលប្រចាំការ សំភារៈបរិក្ខារ មន្ទីរ/បន្ទប់ពិសោធន៍ និងមន្ទីរពេទ្យគ្រប់គ្រាន់។ល។

-ធ្វើយុទ្ធនាការផ្សព្វផ្សាយ និង Branding តាមរយៈការរៀបចំបង្កើតឡាបិល **"គោលដៅទេសចរណ៍សុវត្ថិភាព និងបៃតង" (Safe & Green Cambodia)** សំដៅបង្កើនទំនុកចិត្ត និងភាពជឿជាក់របស់ភ្ញៀវទេសចរ ដើម្បីទាក់ទាញឱ្យមកកម្សាន្តនៅគោលដៅទេសចរណ៍សុវត្ថិភាព ***(ដូចមានក្នុងឧបសម្ព័ន្ធ៦)***។

-រៀបចំ និងពង្រឹង**យន្តការអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (DMO)** ពិសេសសម្រាប់តំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព សំដៅពង្រឹងសកម្មភាព ប្រកបដោយប្រសិទ្ធភាពខ្ពស់ឆ្លើយតបនឹងតម្រូវការរបស់វិស័យទេសចរណ៍ ក្នុងបរិបទថ្មី។

-ពង្រឹងយន្តការគ្រប់គ្រងតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ដោយត្រូវពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការច្បាប់ វិធានការរដ្ឋបាល វិធានការសុខាភិបាល និងវិធានការអប់រំនានា ដែលមានជាធរមាន និងវាយតម្លៃជាប្រចាំនូវសមត្ថភាពទទួលទេសចរណ៍វ៉ាក់សាំង ដើម្បីជាមូលដ្ឋានក្នុងការដាក់ចេញ**យុទ្ធសាស្ត្រត្រឡប់** ឬបន្ធូរបន្ថយវិធានការក្នុងការគ្រប់គ្រងតំបន់នោះ។

## ៦. យន្តការអនុវត្ត

**(៣០)** ការអនុវត្ត**ផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង** នេះ គឺត្រូវមានការគិតគូរប្រកបដោយស្មារតីបុរេសកម្ម និងប្រុងប្រយ័ត្ន ដោយត្រូវមានជាជម្រើសសម្រាប់ **"ការបើក-ការបិទ"** នៅក្នុង

ជំហាននីមួយៗ ទៅតាមការវិវត្តនៃសភាពការណ៍ជាក់ស្តែង។ **ជម្រើសសម្រាប់ការបើក-ការបិទ** នឹងផ្តោតសំខាន់លើ**ទិដ្ឋភាពចំនួន ០៣** រួមមាន÷

**ក. ទិដ្ឋភាពនៃការបែងចែកតំបន់÷**ការបើកទទួលទេសចរណ៍វ៉ាក់សាំង គឺធ្វើឡើង ជាជំហានៗ តាមតំបន់នីមួយៗ ដែលក្នុងនោះលទ្ធភាពបើក ឬបិទ គឺអាស្រ័យលើការអនុវត្តវិធីសាស្ត្រសម្រាប់ការជ្រើសរើស ដែលមានសូចនាករសមិទ្ធកម្មច្បាស់លាស់ ផ្សារភ្ជាប់ជាមួយបុរេលក្ខខណ្ឌ និងនីតិវិធីគ្រប់ជ្រុងជ្រោយ ដែលត្រូវមានការធ្វើបច្ចុប្បន្នភាពជាប់ជាប្រចាំ ស្របតាមការវិវត្តនៃសភាពការណ៍ជាក់ស្តែង។ ការអនុវត្តនេះគឺជាចន្ទល់យុទ្ធសាស្ត្រមួយដែលផ្តល់លទ្ធភាពដល់ការបើក-បិទ តំបន់ ឬគោលដៅ ករណីមានបាតុភាពមិនល្អ ដោយមានការរកឃើញករណីវិជ្ជមានវីរុសកូវីដ-១៩ ពិសេស**វីរុសបំប្លែងថ្មី** ក្នុងចំនួនមិនអាចគ្រប់គ្រងបាន ដែលនឹងធ្វើឱ្យការវាយតម្លៃខុសពីសូចនាករសមិទ្ធកម្មនៃវិធីសាស្ត្រកំណត់ ហើយចំណុចនេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់តំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាពផ្សេងទៀតនោះទេ។

**ខ. ទិដ្ឋភាពនៃការធ្វើអាទិភាវូបនីយកម្មជម្រើសសកម្មភាពទេសចរណ៍÷** ក្រៅពីការបែងចែកកំណត់តំបន់ជំហាននីមួយៗនឹងរៀបចំជ្រើសរើសទៅ**តាមអនុវិស័យ តាមសកម្មភាពទេសចរណ៍** (Selectivity Aspect) ដោយពិចារណាលើកម្រិតនៃអាទិភាព អត្ថប្រយោជន៍ផ្នែកសង្គម-សេដ្ឋកិច្ច លទ្ធភាពគ្រប់គ្រង និងដំណើរការព្រមទាំងឥទ្ធិពល/ផលប៉ះពាល់ ដោយគួរផ្តល់អាទិភាពដល់សកម្មភាព ដែលជាសេវា និងផលិតផលទេសចរណ៍មានហានិភ័យនៃការចម្លងទាប។ ការអនុវត្តនេះនឹងផ្តល់លទ្ធភាពដល់ការអនុញ្ញាតឱ្យបើកដំណើរការ ឬបិទផលិតផល និងសេវាកម្មទេសចរណ៍ នៅតាមតំបន់ ឬគោលដៅទទួលទេសចរណ៍សុវត្ថិភាព ទៅតាមជំហាន និងការវិវត្តជាក់ស្តែងនៃសភាពការណ៍។

**គ. ទិដ្ឋភាពនៃកត្តាពេលវេលា÷** ការអនុវត្តជាជំហានៗនឹងផ្តល់លទ្ធភាពសម្រាប់ការធ្វើតេស្តគម្រោងសាកល្បងបើកទទួលទេសចរណ៍វ៉ាក់សាំង ដើម្បីប្រើប្រាស់ជាបទពិសោធន៍ក្នុងការអនុវត្តសម្រាប់ជំហានបន្តបន្ទាប់ ដោយមិនទាន់អាចបើកទទួលភ្ញៀវទេសចរអន្តរជាតិឡើងវិញ នៅគ្រប់គោលដៅ ក្នុងពេលតែមួយនោះទេ។ ទិដ្ឋភាពពេលវេលា (Timing Aspect) គឺមានសារៈសំខាន់ណាស់ ដើម្បីមានពេលវេលាគ្រប់គ្រាន់ សម្រាប់ការត្រួតពិនិត្យឡើងវិញលើការអនុវត្ត ដោយត្រូវកែសម្រួល ពង្រឹងបន្ថែម ឬបន្ធូរបន្ថយវិធានការនានា តាមការចាំបាច់។

**(៣១)** ជាមួយគ្នានេះផងដែរ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យមានប្រសិទ្ធភាព ចាំបាច់តម្រូវឱ្យមានការចូលរួមពីតួអង្គពាក់ព័ន្ធសំខាន់ៗ ដោយឈរលើ**គោលការណ៍ 4Ps** (Public-Private-People-Partners) រួមមាន ផ្នែករដ្ឋ ផ្នែកឯកជន ប្រជាពលរដ្ឋមូលដ្ឋាន និងភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងប្រទេសជាដៃគូនៅក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី ក្នុងនោះតួអង្គសំខាន់ៗមានដូចខាងក្រោម÷

- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩, គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- ប្រតិបត្តិករទេសចរណ៍ និងអ្នកជំនាញបម្រើការងារក្នុងវិស័យទេសចរណ៍
- ប្រជាពលរដ្ឋម្ចាស់ផ្ទះ និងភ្ញៀវទេសចរជាតិ និងអន្តរជាតិ
- ប្រទេសជាដៃគូ ក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី។

- **តួនាទីរដ្ឋ**

**(៣២)** រាជរដ្ឋាភិបាលដាក់ចេញ និងជំរុញការអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពនានា ដែលមានចង្អុលបង្ហាញនៅក្នុង ផែនការយុទ្ធសាស្ត្រនេះ តាមរយៈតួនាទីភារកិច្ចរបស់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ គណៈកម្មការជាតិ និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីជំរុញការបើកទទួលទេសចរណ៍វ៉ាក់សាំង ដោយឈរលើគោលការណ៍រក្សាបាននូវតុល្យភាពរវាងសកម្មភាពសង្គម-សេដ្ឋកិច្ច និងការធានាសុវត្ថិភាព និងសុខភាពសាធារណៈ សម្រាប់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ និងអ្នកដំណើរគ្រប់ប្រភេទ។

- **តួនាទីវិស័យឯកជន**

**(៣៣)** ប្រតិបត្តិករទេសចរណ៍ និងមូលដ្ឋានអាជីវកម្មទេសចរណ៍ត្រូវត្រៀមខ្លួនសម្របគំរូអាជីវកម្ម **តាមគន្លងប្រក្រតីភាពថ្មី** ដោយអនុវត្តឱ្យបានហ្មត់ចត់នូវវិធានសុវត្ថិភាព និងនីតិវិធីប្រតិបត្តិស្តង់ដា SOP នានា របស់ក្រសួងទេសចរណ៍ និងក្រសួងសុខាភិបាល។ ជាមួយគ្នានេះផងដែរ ប្រតិបត្តិករទេសចរណ៍ត្រូវបន្តពង្រឹងគុណភាពសេវាកម្ម និងផលិតផលរបស់ខ្លួន ដូចជា ការកែលម្អទីតាំង សម្បទា, បណ្តុះបណ្តាលបុគ្គលិក, សម្របគំរូអាជីវកម្ម និងការអនុវត្តតាមបរិបទថ្មី ព្រមជាមួយការខិតខំផ្តល់ជូនតម្លៃប្រកួតប្រជែង។

- **តួនាទីប្រជាពលរដ្ឋ និងភ្ញៀវទេសចរជាតិ-អន្តរជាតិ**

**(៣៤)** ការផ្សព្វផ្សាយ និងអប់រំការយល់ដឹងជាសាធារណៈដល់ប្រជាពលរដ្ឋមូលដ្ឋាននៅតាមតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ពិតជាមានសារៈសំខាន់ណាស់ ក្នុងការកៀរគរការគាំទ្រ និងការចូលរួមពីប្រជាពលរដ្ឋម្ចាស់ផ្ទះសម្រាប់ដំណើរការបើកទទួលភ្ញៀវទេសចរអន្តរជាតិឡើងវិញនៅក្នុងតំបន់ដែលពួកគាត់រស់នៅ។ ប្រជាពលរដ្ឋមូលដ្ឋាន ត្រូវត្រៀមខ្លួនក្នុងការចូលរួមអនុវត្តតាមវិធានការ និងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ព្រមទាំងស្តារសកម្មភាពសង្គម-សេដ្ឋកិច្ចតាមគន្លងប្រក្រតីភាពថ្មី ដោយត្រូវចូលរួមទទួលការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩, និងត្រូវចូលរួមអនុវត្តតាមវិធានសុខាភិបាល វិធានការរដ្ឋបាល និងវិធានការច្បាប់ ឱ្យបានហ្មត់ចត់។ រីឯភ្ញៀវទេសចរក៏មានតួនាទីសំខាន់ក្នុងការចូលរួម និងអនុវត្តតាមវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដា (SOP) សម្រាប់ការធ្វើដំណើរទេសចរណ៍វ៉ាក់សាំង តាមគន្លងប្រក្រតីភាពថ្មី។

- **ភាពជាដៃគូនៅក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី**

**(៣៥)** កិច្ចសហប្រតិបត្តិការនៅក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី ជាមួយបណ្តាប្រទេសដែលជាប្រភពទីផ្សារទេសចរណ៍សំខាន់ៗសម្រាប់កម្ពុជា គឺពិតជាមានភាពចាំបាច់ដើម្បីអាចសម្រេចបានការបើកទទួលទេសចរណ៍វ៉ាក់សាំង តាមរយៈការចែករំលែកព័ត៌មាន ក៏ដូចជាការជំរុញចលនាទេសចរណ៍រវាងគ្នា ជាមួយការបញ្ជាក់ពីភាពរឹងមាំក្នុងការគ្រប់គ្រង និងបង្ការការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតាមតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព។

## ៧. ធនធានហិរញ្ញវត្ថុ

**(៣៦)** ដើម្បីធានាបានជោគជ័យ និងនិរន្តរភាពនៃការបើកទទួលទេសចរណ៍វ៉ាក់សាំង រាជរដ្ឋាភិបាលនឹងធ្វើការសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់ប្រភពថវិកា និងហិរញ្ញប្បទានសក្តានុពល សម្រាប់ទ្រទ្រង់ដល់ការអនុវត្តតាមសកម្មភាពយុទ្ធសាស្ត្រនីមួយៗនៃផែនការយុទ្ធសាស្ត្រនេះ។

**(៣៧)** លទ្ធភាពស្វែងរកប្រភពថវិកា និងហិរញ្ញប្បទាន រួមមាន÷

- **(ទី១). ប្រភពថវិការដ្ឋ**
  - ❖ ថវិការដ្ឋប្រចាំឆ្នាំ
  - ❖ កញ្ចប់ថវិកាសង្គ្រោះ និងកញ្ចប់ថវិកាអន្តរាគមន៍ពិសេស
- **(ទី២). ប្រភពថវិកា និងហិរញ្ញប្បទានពីវិស័យឯកជន ទាំងក្នុងស្រុក និងក្រៅស្រុក**
  - ❖ ការវិនិយោគក្នុងវិស័យទេសចរណ៍ដោយវិនិយោគិនក្នុងស្រុក
  - ❖ ការវិនិយោគផ្ទាល់ពីបរទេស
- **(ទី៣). ប្រភពថវិកា និងហិរញ្ញប្បទានស្របច្បាប់នានា។**

## ៨. យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

### ៨.១ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**(៣៨)** ផែនការយុទ្ធសាស្ត្រនេះត្រូវបានចាត់ទុកជាឯកសាររស់ ដោយត្រូវធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ទៅតាមបរិការណ៍ថ្មី ស្របតាមនិន្នាការវិវត្តនៃចរន្តទេសចរណ៍តំបន់ និងសកលលោក ដែលមានលក្ខណៈបត់បែន និងប្រែប្រួលខ្លាំង តាមការវិវត្តនៃស្ថានភាពរាលដាលនៃជំងឺកូវីដ-១៩។

**(៣៩)** ផែនការយុទ្ធសាស្ត្រនេះ ត្រូវតាមដាន និងត្រួតពិនិត្យការអនុវត្តដោយ**គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.ប.ក.)** និង**គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍** ដែលមាន **ក្រុមការងាររាជរដ្ឋាភិបាលនិងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩** ជាសេនាធិការដែលត្រូវរៀបចំ**សូចនាករគន្លឹះ** សម្រាប់តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពនីមួយៗ ព្រមទាំងរៀបចំរបាយការណ៍លទ្ធផលជូន **គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍** និង **គ.ប.ក.** ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ។

**(៤០)** ភាពជោគជ័យនៃការដាក់ចេញ និងអនុវត្តផែនការយុទ្ធសាស្ត្រនេះ ក៏ប្រឈមនឹងហានិភ័យ ឬវិបត្តិ ដែលកើតឡើងជាប្រធានស័ក្តិ ដែលទាមទារឱ្យមានការវាយតម្លៃ និងគ្រប់គ្រងហានិភ័យជាចាំបាច់។

### ៨.២ ការវាយតម្លៃហានិភ័យ

**(៤១)** ខាងក្រោមនេះជាការវាយតម្លៃហានិភ័យខាងក្រៅ និងខាងក្នុង ដែលអាចជះឥទ្ធិពលដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ÷

**(ទី១)**-ភាពមិនប្រាកដប្រជានៃការរីករាលដាលជំងឺកូវីដ-១៩ នៅកម្រិតសកល និងតំបន់ ដែលអត្រាចម្លងនៅតែបន្តអូសបន្លាយយូរមិនថមថយ និងកាន់តែរីករាលដាលខ្លាំងឡើងៗ។

**(ទី២)-**ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល និងការថមថយនៃអំណាចទិញរបស់ប្រជាជន ពិសេសក្រុមវណ្ណៈកណ្តាល អាចបង្កផលប៉ះពាល់ដល់ការសម្រេចចិត្តរបស់ភ្ញៀវទេសចរអន្តរជាតិចំពោះការធ្វើដំណើរកម្សាន្តចេញក្រៅប្រទេស ដោយប្តូរទៅជាការធ្វើដំណើរក្នុងស្រុកជំនួសវិញ។

**(ទី៣)-**ការវិវត្តលឿននៃជំងឺកូវីដ-១៩ ដោយវីរុសនេះកកើត និងបំប្លែងប្រភេទវីរុសថ្មីៗ ដែលអាចគំរាមកំហែងដល់កម្ពុជា ពិសេសតម្រូវឱ្យមានគិតគូរពីការបន្ថែមប្រសិទ្ធភាពរបស់វ៉ាក់សាំង តាមរយៈការចាក់ដូសជំរុញ។

**(ទី៤)-**ភាពធ្ងន់ធ្ងរនៃវិបត្តិនៅក្នុងវិស័យអាកាសចរណ៍ និងការដឹកជញ្ជូន ដែលបង្កឱ្យក្រុមហ៊ុនអាកាសចរណ៍នៅមិនទាន់អាចត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការបើកដំណើរការប្រតិបត្តិការឡើងវិញបានពេញលេញ និងបំពេញតម្រូវការសម្រាប់ការបើកទទួលទេសចរណ៍វ៉ាក់សាំងនេះទាន់ពេលវេលា។

**(ទី៥)-**ស្ថានភាពអូសបន្លាយនៃការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងប្រទេសនៅតែបន្ត ខណៈដែលករណីឆ្លងរាប់រយក្នុងសហគមន៍កើនឡើងជាបន្តបន្ទាប់ បង្កឱ្យមានសម្ពាធខ្លាំងលើប្រភពធនធានហិរញ្ញវត្ថុ ចំនួនពេទ្យ សមត្ថភាពព្យាបាល មន្ទីរពេទ្យ និងសម្ភារគាំទ្រនានា ដែលជាបច្ច័យធ្វើឱ្យមានភាពស្មុគស្មាញសម្រាប់ការបើកទទួលទេសចរវ៉ាក់សាំង។

**(ទី៦)-**ការគ្រប់គ្រងស្ថានភាព និងសភាពការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងផ្ទៃប្រទេសមិនបានល្អ ដែលនេះគឺជាហានិភ័យមួយដែលនឹងមិនអាចឱ្យយើងមានលទ្ធភាពសម្រាប់ការទាក់ទាញ និងបើកទទួលទេសចរវ៉ាក់សាំងនោះឡើយ។

**(ទី៧)-**ភាពផុយស្រួយនៃឧស្សាហកម្មទេសចរណ៍ក្នុងប្រទេស ដោយសារការបិទ និងការព្យួរអាជីវកម្មក្នុងចំនួនមួយដ៏ច្រើននៅក្នុងផ្នែកខ្លះនៃឧស្សាហកម្មទេសចរណ៍ ដូចជាសណ្ឋាគារ ភោជនីយដ្ឋាន ជាដើម មិនទាន់អាចត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមជំហានដែលបានកំណត់(ឧទា. បុគ្គលិកបាត់បង់ជំនាញ ឬកង្វះបុគ្គលិកសម្រាប់ដំណើរការឡើងវិញ ជាដើម)។

**(ទី៨)-**ថ្លៃផលិតផល និងសេវាកម្មទេសចរណ៍ដែលកំណត់ដោយប្រតិបត្តិករទេសចរណ៍ មិនទាន់មានភាពប្រកួតប្រជែង នៅក្នុងដំណាក់កាលចំពោះមុខ ដែលធ្វើឱ្យកម្ពុជាបាត់បង់នូវភាពទាក់ទាញចំពោះទេសចរអន្តរជាតិលើផ្នែកភាពរំញោចនៃថ្លៃ។

### ៨.៣ ការគ្រប់គ្រងហានិភ័យ

**(៤២)** ដើម្បីគ្រប់គ្រងហានិភ័យ ទាំងខាងក្នុង និងក្រៅ ដូចបានរៀបរាប់ខាងលើ ផែនការយុទ្ធសាស្ត្រនេះ បានកំណត់នូវកត្តាគ្រប់គ្រងហានិភ័យដូចខាងក្រោម÷

**(ទី១)-**ការដាក់ចេញវិធានការត្រឹមត្រូវ និងទាន់ពេលវេលា ដោយរាជរដ្ឋាភិបាល ក្រសួង-ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច។

**(ទី២)-**ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងវិបត្តិនៃជំងឺកូវីដ-១៩ ក្នុងបរិការណ៍ថ្មីនេះ តាមរយៈការពង្រឹងការអនុវត្តច្បាប់ ផែនការយុទ្ធសាស្ត្រ សកម្មភាព និងវិធានការនានា ដែលរាជ-

រដ្ឋាភិបាល និងក្រសួង-ស្ថាប័នពាក់ព័ន្ធបានដាក់ចេញជាបន្តបន្ទាប់ដើម្បីបង្ការ ទប់ស្កាត់ និងកាត់បន្ថយការរីករាលដាលជំងឺកូវីដ-១៩ ក៏ដូចជាការបង្កើនសមត្ថភាពព្យាបាល។

**(ទី៣)-** ស្មារតីទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច ស្ថាប័ននីមួយៗ អង្គភាពនីមួយៗ គ្រប់លំដាប់ថ្នាក់ និងការអនុវត្តអភិបាលកិច្ចរឹងមាំគ្រប់កម្រិត។

**(ទី៤)-** ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី ជាមួយប្រទេសជាដៃគូ និងអង្គការជាតិ-អន្តរជាតិ។

**(ទី៥)-** ការចូលរួម និងការទទួលខុសត្រូវរបស់ផ្នែកឯកជន បុគ្គលម្នាក់ៗ និងភាគីពាក់ព័ន្ធទាំងអស់។

## ៩. សេចក្ដីសន្និដ្ឋាន

**(៤៣)** វិបត្តិនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំង មិនធ្លាប់មានក្នុងរយៈពេល៣០ឆ្នាំចុងក្រោយ លើការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ក្នុងស្មារតីបុរេសកម្ម និងហ្មត់ចត់ តាមរយៈការដាក់ចេញជាបន្តបន្ទាប់នូវវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការច្បាប់ កម្ពុជាពិតជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩បានល្អប្រសើរ។ ក្នុងន័យនេះ ការរៀបចំ **"ផែនការយុទ្ធសាស្ត្រ ស្ដីពី ការបើកទទួលទេសចរណ៍វ៉ាក់សាំង"** គឺជាកិច្ចការដ៏ចាំបាច់ និងចំពេលវេលា ដែលនឹងអនុញ្ញាតឱ្យកម្ពុជាអាចចាប់ផ្ដើមបើកទទួលភ្ញៀវទេសចរអន្តរជាតិឡើងវិញ ជាជំហានៗ តាមគន្លងប្រក្រតីភាពថ្មី សំដៅចូលរួមដល់កិច្ចខិតខំប្រឹងប្រែងក្នុងការស្ដារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ទាំងក្នុង និងក្រោយដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩។

**(៤៤)** ជាមួយគ្នានេះផងដែរ ការរៀបចំផែនការយុទ្ធសាស្ត្រនេះគឺជាការចាប់យកឱកាសក្នុងការប្រែក្លាយវិបត្តិទៅជាកាលានុវត្តភាព សម្រាប់ការដាក់ចេញនូវកំណែទម្រង់ស៊ីជម្រៅ សំដៅប្រែក្លាយកម្ពុជាជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព សុវត្ថិភាព និងមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងបរិយាប័ន្ន ដែលនឹងផ្ដល់ផ្លែផ្កាចូលរួមទ្រទ្រង់ដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចជាតិពីវិបត្តិនៃជំងឺកូវីដ-១៩ ផងដែរ។

**(៤៥)** ដើម្បីឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រនេះទទួលបានជោគជ័យ ចាំបាច់ណាស់ត្រូវទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដោយឈរលើគោលការណ៍ចតុភាគី **"រដ្ឋ-ឯកជន-ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ-ដៃគូនៅក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី"** ដើម្បីបើកទទួលទេសចរណ៍វ៉ាក់សាំង ស្របតាមទិសស្លោក **"ទាំងអស់គ្នា រួមគ្នា យើងនឹងឆ្លងផុតគ្រាលំបាកនេះជាមួយគ្នា"** និងឆ្ពោះទៅភាពរីកចម្រើនរុងរឿងនៃ **"កម្ពុជា÷ព្រះរាជាណាចក្រអច្ឆរិយៈ"**៕

# សទ្ទានុក្រម

- **ទេសចរ (Tourist)** សំដៅដល់បុគ្គល ទាំងឡាយ ជាជនជាតិកម្ពុជា ឬជនបរទេស ដែលមកដល់តំបន់ផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ ស្នាក់នៅទីនោះចាប់ពីមួយយប់ឡើងទៅ និងមិនលើសពីរយៈពេលដែលកំណត់ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ព្រមទាំងមិនទាក់ទងដល់គោលបំណងតាំងទីលំនៅ ឬធ្វើសកម្មភាពណាមួយដែលទទួលបានប្រាក់កម្រៃនៅទីនោះ។ *(យោងតាមច្បាប់ស្តីពីទេសចរណ៍)*
- **អ្នកដំណើរ (Traveler)** សំដៅដល់បុគ្គលទាំងឡាយដែលធ្វើដំណើរចេញពីកន្លែងមួយ ទៅទីតាំងណាមួយផ្សេងទៀត សម្រាប់គោលបំណងផ្សេងៗ និងសម្រាប់រយៈពេលណាមួយ។ *(យោងតាម**អង្គការទេសចរណ៍ពិភពលោក** - UNWTO)*
- យោងតាម**អនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦** ប្រភេទទិដ្ឋាការនីមួយៗ ត្រូវបានកំណត់ដូចខាងក្រោម÷
    - **ទិដ្ឋាការទេសចរណ៍ (ប្រភេទ T)** ជាទិដ្ឋាការសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលជាទេសចរ សម្រាប់ចូល ចេញ តែមួយដង។
    - **ទិដ្ឋាការទូត (ប្រភេទ A)** ជាទិដ្ឋាការសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលកាន់លិខិតឆ្លងដែនការទូត និងក្រុមគ្រួសារ។
    - **ទិដ្ឋាការផ្លូវការ (ប្រភេទ B)** ជាទិដ្ឋាការសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលកាន់លិខិតឆ្លងដែលផ្លូវការមកបំពេញបេសកកម្មក្នុងក្របខណ្ឌរដ្ឋ ឬក្នុងក្របខណ្ឌអង្គការអន្តរជាតិនានា ដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
    - **ទិដ្ឋាការបោរីភាព (ប្រភេទ C)** ជាទិដ្ឋាការសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត និងក្រុមគ្រួសារ ដែលក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងនានាចាត់ទុកជាកិច្ចសហ-ប្រតិបត្តិការ ឬការសម្តែងការគួរសម។
    - **ទិដ្ឋាការធម្មតា (ប្រភេទ E)** ជាទិដ្ឋាការសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលមិនស្ថិតក្នុងប្រភេទទិដ្ឋាការណាមួយ សម្រាប់ចូលចេញតែមួយដង។
    - **ទិដ្ឋាការពិសេស (ប្រភេទ K)** ជាទិដ្ឋាការសម្រាប់ផ្តល់ចំពោះជនដែលមានសញ្ជាតិខ្មែរពីកំណើត ហើយកាន់លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរបរទេស។
- **ចត្តាឡីស័កក្នុងតំបន់** សំដៅដល់ការតម្រូវឱ្យដាក់ខ្លួននៅដាច់ដោយឡែក ស្របតាមវិធានសុខាភិបាល សម្រាប់រយៈពេលកំណត់មួយ នៅក្នុងតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ដែលបានកំណត់ដោយរាជរដ្ឋាភិបាល។ ភ្ញៀវទេសចរ និងអ្នកដំណើរ ដែលត្រូវធ្វើចត្តាឡីស័កក្នុងតំបន់ អាចដើរកម្សាន្តតាមខ្សែទស្សនកិច្ចដែលរៀបចំទុកជាមុន (ចំពោះភ្ញៀវទេសចរដែលមកតាមកញ្ចប់ទស្សនកិច្ច) ឬអាចដើរកម្សាន្តបានដោយសេរីនៅក្នុងបរិវេណនៃតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ដោយត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានសុវត្ថិភាព

និងគោរពតាមការណែនាំនានារបស់រាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ច។ ការចល័តរបស់ភ្ញៀវទេសចរ និងអ្នកដំណើរ នឹងត្រូវស្ថិតក្រោមការគ្រប់គ្រងតាមដានច្បាស់លាស់ ដោយប្រើប្រាស់បច្ចេកវិទ្យា។ ជាមួយគ្នានេះផងដែរ សកម្មភាព និងមូលដ្ឋានអាជីវកម្មទេសចរណ៍ដែលត្រូវបានអនុញ្ញាតឱ្យបើកដំណើរ ស្របតាមជំហាននៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ នឹងត្រូវទទួលការត្រួតពិនិត្យការអនុវត្តវិធានសុវត្ថិភាព ស្របតាមគន្លងប្រក្រតីភាពថ្មី ជាប់ជាប្រចាំ។ នៅពេលបញ្ចប់រយៈពេលចត្តាឡីស័ក ភ្ញៀវដែលមិនមានជំងឺកូវីដ-១៩ អាចចាកចេញពីកម្ពុជា ឬបន្តដំណើរទៅកាន់គោលដៅទេសចរណ៍ផ្សេងទៀត។

- **កញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំងកូវីដ-១៩** សំដៅដល់កម្មវិធីដំណើរកម្សាន្តដែលស្ថិតក្រោមការគ្រប់គ្រងច្បាស់លាស់ក្នុងរង្វង់នៃគោលដៅទស្សនា និងសេវាកម្មដែលត្រូវបានរៀបចំវាយតម្លៃជ្រើសរើសទុកជាមុន និងរៀបចំឡើងដោយក្រុមហ៊ុនទេសចរណ៍ ឬការីទេសចរណ៍ ដោយមានការសហការពីភាគីពាក់ព័ន្ធ។ កញ្ចប់ទស្សនកិច្ចនេះ អាចជាទម្រង់មួយនៃការធ្វើដំណើរ ក្រោមរូបភាព Travel Bubble ដោយមានការព្រមព្រៀងគ្នារវាងប្រទេស និងប្រទេស នៅក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី។
- **គោលដៅទេសចរណ៍សុវត្ថិភាព** សំដៅដល់គោលដៅទេសចរណ៍ដែលមានការគ្រប់គ្រងច្បាស់លាស់ដើម្បីធានាបានតុល្យភាពរវាងសកម្មភាពនៃការបើកទទួលភ្ញៀវទេសចរអន្តរជាតិឡើងវិញ និងការរក្សាបាននូវសុវត្ថិភាពសុខភាពសាធារណៈរបស់ប្រជាពលរដ្ឋ។ គោលដៅទេសចរណ៍សុវត្ថិភាព នឹងត្រូវកំណត់ដោយផ្អែកលើវិធីសាស្ត្រជាក់លាក់ ដែលមានសូចនាករសមិទ្ធកម្មចំនួន ០៤÷ ១.អត្រានៃការចាក់វ៉ាក់សាំងនៅក្នុងតំបន់, ២.អត្រាអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និងកម្រិតធ្ងន់ និងអត្រាស្លាប់នៃអ្នកជំងឺកូវីដ-១៩, ៣.សមត្ថភាពឆ្លើយតប និងព្យាបាល និងការគ្រប់គ្រងហានិភ័យដែលអាចកើតមានពីវីរុសបំប្លែងថ្មី និង៤.ការត្រៀមខ្លួនរបស់ឧស្សាហកម្មទេសចរណ៍ (ដូចដែលមានបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រនេះ)។

# ឧបសម្ព័ន្ធ

**ផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង** មានសកម្មភាពយុទ្ធសាស្ត្រ ដូចខាងក្រោម÷

| ល.រ. | សកម្មភាពយុទ្ធសាស្ត្រ | ២០២១ | ២០២២ | ២០២៣ | អង្គភាពអនុវត្ត |
|---|---|---|---|---|---|
| I. **ការកំណត់នូវប្រភពទីផ្សារទេសចរណ៍វ៉ាក់សាំង** | | | | | |
| ១.១ | តាមដានហានិភ័យរបស់ប្រភពទីផ្សារទេសចរណ៍សំខាន់ៗសម្រាប់កម្ពុជា ក្នុងការបើកទទួលទេសចរណ៍វ៉ាក់សាំង | √ | √ | √ | – គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩<br>– ក្រសួងសុខាភិបាល |
| ១.២ | រៀបចំផ្តល់ទិដ្ឋាការសម្រាប់ការបើកទទួលទេសចរណ៍វ៉ាក់សាំង តាមប្រភេទទេសចរណ៍នីមួយៗ តាមជំហានៗ ប្រកបដោយសុវត្ថិភាព | √ | √ | √ | – ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>– ក្រសួងសុខាភិបាល<br>– អគ្គនាយកដ្ឋានអន្តោប្រវេសន៍ (ក្រសួងមហាផ្ទៃ)<br>– ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា |
| ១.៣ | លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយបណ្តាប្រទេសដែលជាប្រភពទីផ្សារទេសចរណ៍សំខាន់ៗ សម្រាប់ការបើកទទួលទេសចរណ៍វ៉ាក់សាំង | √ | √ | √ | – ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>– ក្រសួងទេសចរណ៍<br>– ក្រសួងសុខាភិបាល<br>– ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា |
| ១.៤ | សិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅទាក់ទងនឹងទីផ្សារ និងប្រភេទនៃការធ្វើដំណើររបស់ទីផ្សារសំខាន់ៗ និងលើកទឹកចិត្តភ្ញៀវទេសចរអន្តរជាតិដែលមកស្នាក់នៅរយៈពេលយូរ និងភ្ញៀវទេសចរមកម្តងហើយម្តងទៀត តាមរយៈ÷<br>• បង្កើតគោលនយោបាយ "ទិដ្ឋាការទេសចរណ៍ពិសេស" | √ | √ | √ | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>– ក្រសួងទេសចរណ៍<br>– អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |

| | | | | | |
|---|---|---|---|---|---|
| | • ជំរុញភាពទាក់ទាញភ្ញៀវទេសចរស្នាក់នៅរយៈពេលយូរ | √ | √ | √ | – ក្រសួងទេសចរណ៍<br>– ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា |
| ១.៥ | ពង្រឹងសកម្មភាពរបស់**ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា** ដោយប្រែក្លាយជាគ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច | √ | √ | √ | – ក្រសួងទេសចរណ៍<br>– ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

**II. ការគ្រប់គ្រងទេសចរមុនពេលចេញដំណើរ និងពេលមកដល់អាកាសយានដ្ឋានអន្តរជាតិ**

**ក. ផែនការសកម្មភាពសម្រាប់មុនពេលទេសចរចូលកម្ពុជា**

| | | | | | |
|---|---|---|---|---|---|
| ២.១ | បង្កើតប្រព័ន្ធស្នើសុំ**លិខិតអនុញ្ញាតចូលប្រទេសកម្ពុជា** ក្រោមឈ្មោះថា **“Safe Travel Pass”** ជាផ្លូវការ សម្រាប់អ្នកដំណើរ និងភ្ញៀវទេសចរ លើកលែងតែភ្ញៀវដែលស្នើសុំទិដ្ឋាការប្រភេទការទូត ប្រភេទផ្លូវការ ប្រភេទបោរីភាព និងទិដ្ឋាការវិនិយោគ រួមជាមួយការបញ្ជាក់ពីការចាក់វ៉ាក់សាំងប្រឆាំងកូវីដ-១៩គ្រប់ដូស ដោយផ្សារភ្ជាប់ជាមួយនីតិវិធីស្នើសុំទិដ្ឋាការ ដែលមានស្រាប់ ទាំងការស្នើសុំដោយផ្ទាល់នៅតាមបណ្តាស្ថានទូត និងស្ថានកុងស៊ុលរបស់កម្ពុជាប្រចាំនៅបរទេស និងការស្នើសុំទិដ្ឋាការអេឡិចត្រូនិច | √ | | | – គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩<br>– ក្រសួងទេសចរណ៍<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>– អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ២.២ | រៀបចំបង្កើត**ថ្នាលឌីជីថលផ្លូវការសម្រាប់ភ្ញៀវទេសចរធ្វើការស្នើសុំកន្លែងសម្រាប់ការធ្វើចត្តាឡីស័កជាមុន** មុនពេលមកប្រទេសកម្ពុជា | √ | | | – គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩<br>– ក្រសួងសុខាភិបាល<br>– ក្រសួងទេសចរណ៍ |

**ខ. ផែនការសកម្មភាពគ្រប់គ្រងការធ្វើដំណើរតាមផ្លូវអាកាសប្រកបដោយសុវត្ថិភាព**

| | | | | | |
|---|---|---|---|---|---|
| ២.៣ | រៀបចំ **"នីតិវិធីប្រតិបត្តិស្តង់ដា(SOP) តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ក្រុមហ៊ុនអាកាសចរណ៍"** | √ | | | - រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល<br>- ក្រុមហ៊ុនព្រលានយន្តហោះ (SCA)<br>- វិស័យឯកជន |
| ២.៤ | តម្រូវឱ្យចាក់វ៉ាក់សាំងកូវីដ-១៩សម្រាប់បុគ្គលិកបម្រើការងារទាំងអស់របស់ក្រុមហ៊ុនអាកាសចរណ៍ | √ | √ | | - ក្រសួងសុខាភិបាល<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល<br>- វិស័យឯកជន |
| ២.៥ | តម្រូវឱ្យក្រុមហ៊ុនអាកាសចរណ៍ទិញស្តុកឧបករណ៍ និងធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់បុគ្គលិករបស់ខ្លួនក្នុងកម្រិតណាមួយ ដោយផ្តល់អាទិភាពដល់បុគ្គលិកដែលមានរោគសញ្ញា, ទើបត្រឡប់មកពីបរទេស ឬ មានទំនាក់ទំនងញឹកញាប់ផ្ទាល់ជាមួយអតិថិជន។ | √ | √ | √ | - ក្រសួងសុខាភិបាល<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល<br>- វិស័យឯកជន |
| ២.៦ | លើកទឹកចិត្តការប្រើប្រាស់បច្ចេកវិទ្យាដែលមានសុវត្ថិភាព រហ័ស និងប៉ះពាល់តិចតួច | √ | √ | √ | - រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល<br>- វិស័យឯកជន |
| **គ. ផែនការសកម្មភាពគ្រប់គ្រងការមកដល់នៅអាកាសយានដ្ឋានអន្តរជាតិ** | | | | | |
| ២.៧ | រៀបចំ **"នីតិវិធីប្រតិបត្តិស្តង់ដា (SOP) តាមគន្លងប្រក្រតីភាពថ្មីសម្រាប់អាកាសយានដ្ឋាន និងច្រកទ្វារអន្តរជាតិ"** រួមទាំងនីតិវិធីសម្រួលពិសេសដោយឡែកសម្រាប់ភ្ញៀវទេសចរនៅក្នុងកម្មវិធីទេសចរណ៍វ៉ាក់សាំង | √ | | | - រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល<br>- ក្រុមហ៊ុនព្រលានយន្តហោះ (SCA)<br>- រដ្ឋបាលរាជធានី-ខេត្ត<br>- វិស័យឯកជន |
| ២.៨ | បញ្ចូលតួនាទី និងភារកិច្ចរបស់មន្ត្រីសុខាភិបាលក្នុងការវាយតម្លៃហានិភ័យសុខភាពរបស់អ្នកដំណើរ និងភ្ញៀវទេសចរ នៅក្នុងយន្តការត្រួតពិនិត្យនៅតាមច្រកទ្វារអន្តរជាតិ ដែលមានស្រាប់ | √ | | | - គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩<br>- ក្រសួងសុខាភិបាល<br>- អគ្គនាយកដ្ឋានអន្តោប្រវេសន៍<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល |

| | | | | | |
|---|---|---|---|---|---|
| ២.៩ | ប្រើប្រាស់ឧបករណ៍តេស្តរហ័សរក អង់ទីហ្សែនកូវីដ-១៩ ចំពោះភ្ញៀវទេសចរស្ថិតក្នុងកម្មវិធីទេសចរណ៍វ៉ាក់សាំង នៅច្រកទ្វារអន្តរជាតិ និងរៀបចំកន្លែងសមរម្យសម្រាប់រង់ចាំលទ្ធផលតេស្ត | √ | √ | √ | – ក្រសួងសុខាភិបាល<br>– រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល<br>– អគ្គនាយកដ្ឋានអន្តោប្រវេសន៍<br>– ក្រុមហ៊ុនព្រលានយន្តហោះ (SCA)<br>– វិស័យឯកជន |
| ២.១០ | បណ្តុះបណ្តាលដល់អាជ្ញាធរមានសមត្ថកិច្ចដែលនៅជួរមុខតាមច្រកទ្វារអន្តរជាតិទាំងអស់ត្រូវយល់ដឹងអំពី **"គន្លងប្រក្រតីភាពថ្មី"** ដោយយកចិត្តទុកដាក់ជាប្រចាំនូវការរក្សាគម្លាតសុវត្ថិភាព ពាក់ម៉ាសការពារ រក្សាអនាម័យ លាងដៃនឹងសាប៊ូ អាកុល ឬជែល និងប្រុងប្រយ័ត្នការឆ្លងពីអ្នកដំណើរ និងភ្ញៀវទេសចរដែលចេញ-ចូលតាមច្រកទ្វារអន្តរជាតិ | √ | √ | √ | – គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩<br>– ក្រសួងសុខាភិបាល<br>– គណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស (គ.អ.ច.ទ.)<br>– រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល<br>– អគ្គនាយកដ្ឋានអន្តោប្រវេសន៍ (ក្រសួងមហាផ្ទៃ) |
| ២.១១ | រៀបចំសៀវភៅណែនាំដល់អ្នកដំណើរ និងភ្ញៀវទេសចរ អំពី **"ប្រការគួរធ្វើ និងមិនគួរធ្វើ" (Do & Don't)** នៅតាមច្រកទ្វារអន្តរជាតិ និងផ្តល់ព័ត៌មានងាយស្រួលស្វែងរក អំពីនីតិវិធីប្រតិបត្តិស្តង់ដា (SOP), វិធានសុវត្ថិភាពទេសចរណ៍, វិធានសុខាភិបាល | √ | | | – ក្រសួងទេសចរណ៍<br>– គ.អ.ច.ទ.<br>– រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល<br>– ក្រុមហ៊ុនព្រលានយន្តហោះ (SCA)<br>– វិស័យឯកជន |
| ២.១២ | បង្កើនការប្រើប្រាស់បច្ចេកវិទ្យានៅតាមច្រកទ្វារអន្តរជាតិប្រកបដោយសុវត្ថិភាពរហ័ស និងប៉ះពាល់តិចតួច | √ | √ | √ | – រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល<br>– គ.អ.ច.ទ.<br>– អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |

| | | | | | |
|---|---|---|---|---|---|
| | | | | | - ក្រុមហ៊ុនព្រលានយន្តហោះ (SCA) |
| **ឃ. ផែនការសកម្មភាពគ្រប់គ្រងការធ្វើចត្តាឡីស័ក និងនីតិវិធីសម្របសម្រួលនានា** | | | | | |
| ២.១៣ | រៀបចំយន្តការគ្រប់គ្រង និងសម្រួលដល់អ្នកដំណើរ និងភ្ញៀវទេសចរពីអាកាសយានដ្ឋានទៅកាន់គោលដៅសម្រាប់ការធ្វើចត្តាឡីស័កឱ្យបានហ្មត់ចត់ និងប្រកបដោយសុវត្ថិភាព សម្រាប់អ្នកដែលត្រូវធ្វើចត្តាឡីស័កនៅក្នុងតំបន់ឬគោលដៅទេសចរណ៍សុវត្ថិភាព | √ | √ | √ | - គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩<br>- ក្រសួងសុខាភិបាល<br>- គ.អ.ច.ទ.<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល<br>- រដ្ឋបាលរាជធានី-ខេត្ត |
| ២.១៤ | អនុវត្តវិធានការចត្តាឡីស័កសម្រាប់អ្នកដំណើរ និងភ្ញៀវទេសចរឱ្យបានហ្មត់ចត់ស្របតាមជំហាន និងតំបន់គោលដៅទេសចរណ៍សុវត្ថិភាព | √ | √ | √ | - គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩<br>- ក្រសួងសុខាភិបាល<br>- ក្រសួងទេសចរណ៍<br>- រដ្ឋបាលរាជធានី-ខេត្ត |
| **III. ការត្រៀមលក្ខណៈសម្បត្តិនៃឧស្សាហកម្មទេសចរណ៍ស្របតាមគន្លងប្រក្រតីភាពថ្មី** | | | | | |
| ៣.១ | រៀបចំ **“ពិធីសារស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង”** កំណត់ដោយសេចក្តីសម្រេចរបស់**ក្រុមការងាររាជរដ្ឋាភិបាល និងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា** | √ | | | - ក្រុមការងាររាជរដ្ឋាភិបាល និងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ |
| ៣.២ | ម្ចាស់អាជីវកម្មទេសចរណ៍ ត្រូវឱ្យបុគ្គលិករបស់ខ្លួនចូលរួមក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពជំនាញ (Reskilling) និងការបង្កើនចំណេះដឹងបន្ថែម (Upskilling) | √ | √ | √ | - ក្រសួងទេសចរណ៍<br>- រដ្ឋបាលរាជធានី-ខេត្ត<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>- ក្រុមហ៊ុនព្រលានយន្តហោះ (SCA)<br>- វិស័យឯកជន |
| ៣.៣ | រៀបចំវគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍ ឆ្លើយតបនឹងតម្រូវការតាមគន្លងប្រក្រតីភាពថ្មី និងបដិវត្តន៍ឧស្សាហកម្ម ៤.០ | √ | √ | √ | - ក្រសួងទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |

| | | | | | |
|---|---|---|---|---|---|
| | | | | | - ក្រសួងឧស្សាហកម្ម វិទ្យា-សាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>- សហភាពសហព័ន្ធយុវជនកម្ពុជា<br>- មជ្ឈមណ្ឌលកម្ពុជា ៤.០<br>- វិស័យឯកជន |
| ៣.៤ | សិក្សារៀបចំ និងបន្តដាក់ចេញវិធានការទ្រទ្រង់ថ្មីៗ ផ្នែកសេដ្ឋកិច្ច ដល់ឧស្សាហកម្មទេសចរណ៍ និងកែទម្រង់ស៊ីជម្រៅចំពោះវិស័យទេសចរណ៍កម្ពុជា ស្របតាមជំហាននៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ និងការវិវត្តជាក់ស្ដែងនៃសភាពការណ៍វិបត្តិនៃជំងឺកូវីដ-១៩ | √ | √ | √ | - គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៣.៥ | រៀបចំបង្កើត **“ប្រព័ន្ធកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំងកូវីដ-១៩”** និងការីទេសចរណ៍ទាំងអស់ត្រូវចូលរួមរៀបចំបញ្ចូលគ្រប់ដំណើរកម្សាន្តនីមួយៗឱ្យស្ថិតក្រោមការគ្រប់គ្រងច្បាស់លាស់ មានហានិភ័យទាបប្រកបដោយសុវត្ថិភាព | √ | √ | √ | - ក្រសួងទេសចរណ៍<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- អគ្គនាយកដ្ឋានអន្តោប្រវេសន៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>- វិស័យឯកជន (ការីទេសចរណ៍) |
| ៣.៦ | ជំរុញការរៀបចំសេវាកម្មប្រកបដោយសុវត្ថិភាព ដល់ប្រតិបត្តិករទេសចរណ៍ និងមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ | √ | √ | √ | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>- វិស័យឯកជន |
| ៣.៧ | ប្រតិបត្តិករទេសចរណ៍ទាំងអស់តម្រូវឱ្យបុគ្គលិកខ្លួនទទួលបានការចាក់វ៉ាក់សាំងកូវីដ-១៩ និងទិញស្តុកឧបករណ៍ធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់បុគ្គលិក ព្រមទាំងបញ្ចូល | √ | √ | √ | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>- វិស័យឯកជន |

| | | | | | |
|---|---|---|---|---|---|
| | ទិន្នន័យបុគ្គលិកដែលបានចាក់វ៉ាក់សាំង ទៅក្នុងប្រព័ន្ធ និងត្រូវរៀបចំបង្កើត **ឡាបិល "VACCINATED" នៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់** | | | | |
| ៣.៨ | គ្រប់អាជីវកម្មទេសចរណ៍ដែលធ្លាប់ទទួលបានឡាបិល **"វិធានសុវត្ថិភាពទេសចរណ៍"** ទាំងអស់ ត្រូវធ្វើកិច្ចសន្យាអនុវត្ត និងទទួលបានការវាយតម្លៃដោយចៃដន្យ តាមការចាំបាច់ | √ | √ | √ | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>- វិស័យឯកជន |
| ៣.៩ | រៀបចំបង្កើត និងដាក់អនុវត្ត **"កម្មវិធីតាមដានដំណើរកម្សាន្តរបស់ភ្ញៀវ"** (Tracerapp) សម្រាប់ភ្ញៀវទេសចរអន្តរជាតិ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបង្ការ និងចូលរួមទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ | √ | √ | | - គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត |
| **IV.** | **ការកំណត់ និងគ្រប់គ្រងគោលដៅទេសចរណ៍សុវត្ថិភាព** | | | | |
| ៤.១ | កំណត់ពេលវេលាសម្រាប់ការអនុវត្តជំហាននីមួយៗនៃផែនការយុទ្ធសាស្ត្រស្តីពី ការបើកទទួលទេសចរណ៍វ៉ាក់សាំង | √ | √ | √ | - គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩<br>- ក្រុមការងាររាជរដ្ឋាភិបាលនិងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត |
| ៤.២ | សិក្សាកំណត់តំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព | √ | √ | √ | - គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធ នឹងជំងឺកូវីដ-១៩<br>- ក្រសួងសុខាភិបាល |

| | | | | | |
|---|---|---|---|---|---|
| | | | | | - ក្រសួងទេសចរណ៍<br>- ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី-ខេត្ត<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត |
| ៤.៣ | ដាក់ចេញ**យុទ្ធនាការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩** សម្រាប់មូលដ្ឋានអាជីវកម្មដែលបើកទទួលទេសចរណ៍វ៉ាក់សាំងនៅក្នុងតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ឱ្យបានយ៉ាងតិចណាស់មួយខែម្តង | √ | √ | √ | - ក្រសួងទេសចរណ៍<br>- ក្រសួងសុខាភិបាល<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>- វិស័យឯកជន |
| ៤.៤ | រៀបចំតំបន់គោលដៅទេសចរណ៍សុវត្ថិភាព ដោយត្រូវគិតគូរឱ្យបានហ្មត់ចត់លើហានិភ័យនៃការចម្លងរបស់អ្នកដំណើរ និងភ្ញៀវទេសចរ | √ | √ | √ | - គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធ នឹងជំងឺកូវីដ-១៩<br>- ក្រសួងសុខាភិបាល<br>- ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី-ខេត្ត<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត |
| ៤.៥ | ធ្វើយុទ្ធនាការផ្សព្វផ្សាយ និង Branding តាមរយៈការរៀបចំបង្កើតឡាបិល **"គោលដៅទេសចរណ៍សុវត្ថិភាព និងស្អាត" (Safe & Clean Cambodia)** | √ | √ | √ | - ក្រសួងទេសចរណ៍<br>- ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ |
| ៤.៦ | រៀបចំ និងពង្រឹង**យន្តការអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (DMO)** ពិសេសសម្រាប់តំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព | √ | √ | √ | - គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍<br>- ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>- វិស័យឯកជន |

| | | | | | |
|---|---|---|---|---|---|
| ៤.៧ | ពង្រឹងយន្តការគ្រប់គ្រងតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ដោយត្រូវពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការច្បាប់ វិធានការរដ្ឋបាល វិធានការសុខាភិបាល និងវិធានការអប់រំនានា ដែលមានជាធរមាន និងវាយតម្លៃជាប្រចាំនូវសមត្ថភាពទទួលទេសចរណ៍រាក់សាំង ដើម្បីជាមូលដ្ឋានក្នុងការដាក់ចេញយុទ្ធសាស្ត្រគ្រឡប់ ឬបន្ធូរបន្ថយវិធានការក្នុងការគ្រប់គ្រងតំបន់នោះ | √ | √ | √ | – គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធ នឹងជំងឺកូវីដ-១៩<br>– ក្រសួងមហាផ្ទៃ<br>– ក្រសួងសុខាភិបាល<br>– ក្រសួងទេសចរណ៍<br>– អគ្គស្នងការដ្ឋាននគបាលជាតិ<br>– កងរាជអាវុធហត្ថលើផ្ទៃប្រទេស<br>– រដ្ឋបាលរាជធានី-ខេត្ត |

## ឧបសម្ព័ន្ធទី២៖ ដំណើរការសម្រាប់ការស្នើសុំលិខិតអនុញ្ញាតចូលកម្ពុជា (Safe Travel Pass)




* ការតម្រូវឱ្យស្នើសុំ "លិខិតអនុញ្ញាតចូលកម្ពុជា" ត្រូវបានលើកលែងចំពោះភ្ញៀវដែលស្នើសុំទិដ្ឋាការប្រភេទការទូត (ប្រភេទ A) ផ្លូវការ (ប្រភេទ B) បោរីភាព (ប្រភេទ C) និងទិដ្ឋាការវិនិយោគ (ប្រភេទ E)។




*ការតម្រូវឱ្យស្នើសុំ "លិខិតអនុញ្ញាតចូលកម្ពុជា" ត្រូវបានលើកលែងចំពោះភ្ញៀវដែលស្នើសុំទិដ្ឋាការប្រភេទការទូត (ប្រភេទ A) ផ្លូវការ (ប្រភេទ B) បោរីភាព (ប្រភេទ C) និងទិដ្ឋាការវិនិយោគ (ប្រភេទ E)។

## ឧបសម្ព័ន្ធទី៣៖ ដំណើរការនៃការប្រើប្រាស់ប្រព័ន្ធកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំងកូវីដ-១៩



## ឧបសម្ព័ន្ធទី៤÷ នីតិវិធីបញ្ចូលទិន្នន័យបុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍ដែលបានចាក់វ៉ាក់សាំង

MINISTRY OF TOURISM

CAMBODIA
Kingdom of Wonder

# នីតិវិធីបញ្ចូលទិន្នន័យ

## បុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍ ដែលបានចាក់វ៉ាក់សាំង ការពារជំងឺកូវីដ-១៩ ទៅក្នុងប្រព័ន្ធ Telegram BOT

## រៀបចំដោយ ក្រសួងទេសចរណ៍



### ១. ការស្វែងរក និងបញ្ចូលព័ត៌មានអ្នកប្រើប្រាស់

- បើកដំណើរការកម្មវិធី Telegram ដែលមាននៅលើទូរស័ព្ទដៃ ឬកុំព្យូទ័ររបស់លោកអ្នក
- ស្វែងរកពាក្យ **ទិន្នន័យអ្នកបានចាក់វ៉ាក់សាំង ក្នុងវិស័យទេសចរណ៍** (ក)
- ចុចប៊ូតុង START រួចចុចប៊ូតុង SHARE ដើម្បីផ្តល់ព័ត៌មានលេខទូរស័ព្ទរបស់លោកអ្នកទៅក្រសួងទេសចរណ៍

### ២. បញ្ចូលព័ត៌មានអាជីវកម្ម

- ចុចប៊ូតុង **បន្ថែម និងពិនិត្យទិន្នន័យ** (ខ)
- នោះលោកអ្នកនឹងឃើញប៊ូតុងចំនួន ៤ដូចជា៖
  - បញ្ចូលព័ត៌មានអាជីវកម្ម
  - បញ្ចូលព័ត៌មានបុគ្គលិក
  - កែព័ត៌មានអាជីវកម្ម
  - កែព័ត៌មានបុគ្គលិក
- សូមចុចប៊ូតុង **បញ្ចូលព័ត៌មានអាជីវកម្ម** ដើម្បីធ្វើការបំពេញព័ត៌មានមួយចំនួនពីអាជីវកម្មរបស់លោកអ្នក (គ)

### ៣. បញ្ចូលព័ត៌មានបុគ្គលិក

- សូមចុចប៊ូតុង **បញ្ចូលព័ត៌មានបុគ្គលិក** ដើម្បីធ្វើការបំពេញព័ត៌មានមួយចំនួនរបស់បុគ្គលិកដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ (ឃ)
- រួចធ្វើការបញ្ចូលព័ត៌មានមួយចំនួនរបស់បុគ្គលិកដូចជា៖ រូបថត ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ប្រសិនបើជាជនបរទេស) លេខទូរស័ព្ទ អាសយដ្ឋានបច្ចុប្បន្ន មុខងារ/តួនាទី និងប្រភេទវ៉ាក់សាំងដែលបានចាក់
- រួចចុចប៊ូតុង **រួចរាល់**




- លោកអ្នកត្រូវបញ្ចូលព័ត៌មានរបស់បុគ្គលិក កំពុងបម្រើការងារជាក់ស្តែងដែលបានចាក់វ៉ាក់សាំង**ការពារជំងឺកូវីដ-១៩** រួចរាល់
- លោកអ្នកអាចចុចលើប៊ូតុង **កែព័ត៌មានអាជីវកម្ម** ដើម្បីពិនិត្យព័ត៌មានអាជីវកម្ម និងប៊ូតុង **កែព័ត៌មានបុគ្គលិក** ដើម្បីពិនិត្យព័ត៌មានរបស់បុគ្គលិក ដែលលោកអ្នកបានបញ្ចូលទៅក្នុងប្រព័ន្ធ Telegram BOT នេះ។

ស្កេន Qr Code ដើម្បីចូលក្នុងប្រព័ន្ធ

## ឧបសម្ព័ន្ធទី៥៖ ឡាបិល VACCINATED

បានចាក់វ៉ាក់សាំងរួចរាល់

VACCINATED

COVID-19

## ឧបសម្ព័ន្ធទី៦៖ ឡាបិល តំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព

## សេចក្តីថ្លែងអំណរគុណ

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍**និង **ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍** ចំពោះការណែនាំដល់ក្រុមការងាររៀបចំ ផែនការយុទ្ធសាស្ត្រ ស្តីពី ការបើកទទួលទេសចរណ៍វ៉ាក់សាំង ប្រកបដោយជោគជ័យ។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម ហ៊ុន ម៉ានី ប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍នៃរដ្ឋសភា** ចំពោះការផ្តល់នូវធាតុចូលដ៏មានតម្លៃសម្រាប់ការផ្តួចផ្តើមរៀបចំផែនការយុទ្ធសាស្ត្រ ស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង ក្នុងកិច្ចប្រជុំរវាងគណៈកម្មការទី៧នៃរដ្ឋសភា និងក្រសួងទេសចរណ៍ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ កន្លងមក។

សូមគោរពជូនពរ ឯកឧត្តម សូមទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ។

### ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រ ស្តីពី ការបើកទទួលទេសចរណ៍វ៉ាក់សាំង

| | | |
|---|---|---|
| ១- | **ឯកឧត្តម ណេប សាមុត** | អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងជាប្រធានលេខាធិការដ្ឋាននៃក្រុមការងាររាជរដ្ឋាភិបាល និងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍ ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ |
| ២- | **ឯកឧត្តម អាំង សុវណ្ណរ័ត្ន** | អគ្គនាយករងអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ និងជាអនុប្រធានលេខាធិការដ្ឋាននៃក្រុមការងាររាជរដ្ឋាភិបាល និងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍ ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ |
| ៣- | លោកស្រី ហេង ស្រស់ | អនុប្រធាននាយកដ្ឋានទីភ្នាក់ងារដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍ និងជាសមាជិកនៃលេខាធិការដ្ឋាននៃក្រុមការងាររាជរដ្ឋាភិបាល និងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍ ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ |
| ៤- | លោក សេង វិរៈយុទ្ធ | សមាជិកនៃលេខាធិការដ្ឋាននៃក្រុមការងាររាជរដ្ឋាភិបាល និងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍ ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ |
| ៥- | កញ្ញា ចាន់ ចុនបញ្ញា | នាយការិយាល័យនៃនាយកដ្ឋានវាយតម្លៃក្រុងស្អាត |
| ៦- | លោក មឿន ពន្លក | នាយការិយាល័យនៃនាយកដ្ឋានវាយតម្លៃទីក្រុងស្អាត |
| ៧- | លោក ទូច ផាន់ណា | មន្ត្រីជំនួយការអគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ |

### ក្រុមការងារពិគ្រោះយោបល់

| | | |
|---|---|---|
| ១- | **ឯកឧត្តម ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ២- | **ឯកឧត្តម ហួត ពុំ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៣- | **ឯកឧត្តម ឈាង វណ្ណារិទ្ធ** | អគ្គនាយកគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៤- | **ឯកឧត្តម ទិត ចន្ថា** | រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍ |
| ៥- | **ឯកឧត្តម ជា បូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ |
| ៦- | **ឯកឧត្តម ជា កុសល** | អនុរដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យក្រសួងទេសចរណ៍ |
| ៧- | **ឯកឧត្តម សុខ សង្ហារ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ |
| ៨- | **ឯកឧត្តម ថោង រដ្ឋសក្តិ** | អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ |
| ៩- | **ឯកឧត្តម ឈុន មករា** | អគ្គលេខាធិការរង គ.ជ.វ.ទ. និងជាប្រធាននាយកដ្ឋានទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍ |
| ១០- | **ឯកឧត្តម គីម សេរីរដ្ឋ** | អគ្គលេខាធិការរង គ.ជ.វ.ទ. និងជាប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍ និងម្ហូបអាហារ |
| ១១- | **ឯកឧត្តម ជួន ជ័យសត្យា** | អគ្គលេខាធិការរង គ.ជ.វ.ទ. និងជាប្រធាននាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ |
| ១២- | **ឯកឧត្តម ឆាយ ឃុនឡុង** | ទីប្រឹក្សាក្រសួងទេសចរណ៍ និងជាអគ្គនាយករងគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ |

# រៀបចំដោយ

ក្រុមការងាររាជរដ្ឋាភិបាលនិងឯកជន ដើម្បីស្តារ
និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា
ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩

# សូមថ្លែងអំណរគុណ

គណៈកម្មការអប់រំ យុវជន កីឡា
ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍